

SIPAR

## ខ្ញុំចង់ដឹង







# ជនជាតិខ្មែរ ភាគ២

## ស.វ.ទី១៥–ឆ្នាំ១៩៥៣

និពន្ធដោយ Paul Brunon
និង ស៊ុនហេង ម៉េងឈាង

**អ្នកទទួលខុសត្រូវបោះពុម្ពផ្សាយ :** ហុក សុទ្ធិ
**ប្រតិភូទទួលខុសត្រូវបោះពុម្ពផ្សាយ :** Clotilde Eav
**រចនាទំព័រ :** យ៉ែម ខេមចិត្តធា, ជ្រឹម ហុកស្រ៊ិន
**អ្នកពិនិត្យអត្ថបទ :** ចិន្ត ច័ន្ទរតនា, លិម សន្តិភាព, ហុក សាពាប់ **និង** នេត សុគន្ធា

សៀវភៅនេះបានទទួលការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ **៩២៣ អយក.ប្រក.** ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ដើម្បីអោយបោះពុម្ពផ្សាយ សំរាប់ប្រើប្រាស់ជាសៀវភៅអានបន្ថែម នៅតាមសាលារៀនចំណេះទូទៅ។

# លំដាប់កាលប្រវត្តិ ស.វ.ទី១៥-ឆ្នាំ១៩៥៣




| រជ្ជកាល (គ.ស.) | ព្រះនាមច្រើនប្រើ (នាមផ្សេង) | រាជធានី |
|---|---|---|
| ១៤២១?-១៤៦៣ | ពញាយ៉ាត (បរមរាជាទី២) | អង្គរ ទួលបាសាន ចតុមុខ |
| *១៤៣១* | *ចំណាកចំណោលអង្គរ* | |
| *១៤៣៤* | *ការតាំងរាជធានីនៅចតុមុខ* | |
| | *ទំនាស់ក្នុងរាជវង្ស* | |
| ១៥០៤-១៥១២ | ចៅពញាដាំខាត់រាជា (ស្រីសុគន្ធបទ) | ទួលបាសាន |
| ១៥១២-១៥២៥ | ស្ដេចកន (ស្រីជេដ្ឋាធិរាជ) | ទួលបាសាន ស្រឡប់ពិជ័យ |
| ១៥១៦-១៥៦៦ | ចន្ទរាជា រីអង្គចន្ទទី១ (បរមរាជាទី៣) | ពោធិ៍សាត់ លង្វែក |
| *១៥២៩* | *ការតាំងរាជធានីនៅលង្វែក* | |
| ១៥៦៦-១៥៧៦ | បរមិន្ទរាជា (បរមរាជាទី៤) | លង្វែក |
| ១៥៧៦-១៥៨៦ | សត្ថាទី១ (បរមរាជាទី៥) | លង្វែក |
| *១៥៩៤* | *ការបែកបន្ទាយលង្វែក* | |
| ១៦០៣-១៦១៨ | ស្រីសុរិយោពណ៍ (បរមរាជាទី៨) | កោះស្លាកែត ល្វាឯម |
| ១៦១៨-១៦២៨ | ជ័យជេដ្ឋាទី២ | ឧដុង្គ |
| *១៦២០* | *ការតាំងរាជធានីនៅឧដុង្គ* | |
| ១៦២៩-១៦៣៤ | រាជសំភារ ចៅពញាតូ (ស្រីធម្មរាជាទី២) | កោះឃ្លោក |
| ១៦៤១-១៦៥៩ | ពញាចន្ទ (រាមាធិបតីទី១) | ឧដុង្គ |
| | *វិបត្តិដណ្ដើមរាជសម្បត្តិ មានស្ដេចមិនស្ថិតស្ថេរជាច្រើនអង្គ ហើយស្ដេចខ្លះសោយរាជ្យច្រើនដង* | |
| ១៧៧៩-១៧៩៦ | អង្គអេង (នារាយណ៍រាជាទី៣) | ឧដុង្គ |
| ១៨០៦-១៨៣៤ | អង្គចន្ទទី២ (ឧទ័យរាជា) | ឧដុង្គ ភ្នំពេញ |
| ១៨៣៤-១៨៤០ | អង្គមី | កោះស្លាកែត |
| ១៨៤០-១៨៥៩ | អង្គឌួង | ឃ្លាំងស្បែក ឧដុង្គ |
| ១៨៥៩-១៩០៤ | នរោត្តម | ឧដុង្គ ភ្នំពេញ |
| *១៨៦៣* | *ការដាក់អាណាព្យាបាលបារាំង* | |
| *១៨៦៧* | *ការតាំងរាជធានីនៅភ្នំពេញ* | |
| ១៩០៤-១៩២៧ | ស៊ីសុវត្ថិ | ភ្នំពេញ |
| ១៩២៧-១៩៤១ | ស៊ីសុវត្ថិ មុនីវង្ស | ភ្នំពេញ |
| ១៩៤១-១៩៥៥ | នរោត្តមសីហនុវរ្ម័ន (រជ្ជកាលទី១) | ភ្នំពេញ |
| *១៩៥៣* | *ឯករាជ្យពេញលេញ* | |

# មាតិកា


ទួលបាសាន-រាជធានីបណ្ដោះអាសន្ន មុនក្រុងចតុមុខ ១៤៣១-១៤៣៤ ..... 4
ចតុមុខ-រាជធានីថ្មីរបស់ព្រះបាទពញាយ៉ាត ចាប់ពីឆ្នាំ១៤៣៤ ..... 6
នាយកន-ស្ដេចជ្រែករាជ្យ ១៥១២-១៥២៥ ..... 8
ចន្ទរាជា រីអង្គចន្ទទី១-ស្ថាបនិកក្រុងលង្វែក ១៥១៦-១៥៦៦ ..... 10
បរមរាជា-ឈ្នះសៀម និងលាវ ១៥៦៦-១៥៧៦ ..... 12
អ្នកផ្សាយសាសនា ឈ្មួញ និងទាហានអឺរ៉ុប សតវត្សទី១៦ ..... 14
ការវាយលុករបស់សៀម និងការបែកបន្ទាយលង្វែក ចុងសតវត្សទី១៦ ..... 16
ឥទ្ធិពលបរទេស សតវត្សទី១៧ ..... 18
ជ័យជេដ្ឋាទី២-ស្ថាបនិកក្រុងឧដុង្គ ១៦១៨-១៦២៨ ..... 20
រាជសំភារ ចៅពញាតូ-កវីល្បីឈ្មោះ ១៦២៩-១៦៣៤ ..... 22
ពញាចន្ទ-ព្រះរាជាកាន់សាសនាអ៊ិស្លាម ១៦៤១-១៦៥៩ ..... 23
វិបត្តិដណ្ដើមរាជសម្បត្តិ សតវត្សទី១៧ ..... 24
ទឹកដីខ្មែរក្នុងចំបាំង និងល្បិចកល សតវត្សទី១៨ ..... 26
អង្គអេង ១៧៧៩-១៧៩៦ និង អង្គចន្ទទី២ ១៨០៦-១៨៣៤-ស្ដេចទទួលរាជាភិសេកនៅបាងកក ..... 28
ក្សត្រីអង្គមី-អធិជ័យរបស់យួន ១៨៣៤-១៨៤០ ..... 29
អង្គឌួង-របត់មួយនៃប្រវត្តិសាស្ត្រខ្មែរ ១៨៤០-១៨៥៩ ..... 30
នរោត្តម-ការដាក់អាណាព្យាបាលបារាំង ១៨៥៩-១៩០៤ ..... 32
ស៊ីសុវត្ថិ ១៩០៤-១៩២៧ និង មុនីវង្ស ១៩២៧-១៩៤១-ការបន្តអនុសញ្ញាបារាំង-ខ្មែរ ឆ្នាំ១៨៨៤ ..... 34
នរោត្តមសីហនុវរ្ម័ន-ព្រះបិតាឯករាជ្យជាតិ រជ្ជកាលទី១ : ១៩៤១-១៩៥៥ ..... 36
ការរកឃើញឡើងវិញ និងការជួសជុលអង្គរ ..... 40
ផែនទី ..... 42
ពន្យល់ពាក្យ និងចំលើយ ..... 44


**សំគាល់**

- នៅក្នុងអត្ថបទ ពាក្យដែលមានសំគាល់ដោយសញ្ញា ▬ មានពន្យល់ន័យនៅទំព័រ៤៤ ។
- ឆ្នាំ ដែលមានប្រើក្នុងសៀវភៅនេះ ជាឆ្នាំនៃគ្រិស្តសករាជ ។

# ទួលបាសាន-រាជធានីបណ្ដោះអាសន្ន មុនក្រុងចតុមុខ ១៤៣១-១៤៣៤

**ពញាយ៉ាត**(បរមរាជាទី២) ជាបុត្រព្រះបាទសុរិយោវង្ស។ នៅពេលទ័ពសៀមវាយយកបានក្រុងអង្គរ ទ្រង់បានគេចខ្លួនរត់រួច ហើយនៅកែនទ័ពត្រលប់មករំដោះក្រុងអង្គរបានវិញ។

## ហេតុអ្វី ក៏ ទួលបាសាន ?

ទួលបាសានជាទីតាំងយុទ្ធ-សាស្ត្រមួយដ៏ល្អប្រពៃ ស្ថិតនៅមាត់ទន្លេមេគង្គ ខាងកើតមានបឹងមួយធំ ខាងអាគ្នេយ៍មានទន្លេតូច ខាងត្បូងមានព្រៃញឹក។ ទីតាំងនេះផ្ដល់ការងាយស្រួលក្នុងកិច្ចការពារប្រឆាំងនឹងការវាយលុកមកពីខាងក្រៅ។

## សំណាញ់និងទេថា

ចាប់ពីពេលនោះមក សំណង់ទាំងឡាយលែងធ្វើអំពីថ្មទៀតហើយ តែធ្វើអំពីឈើទាំងអស់ រហូតមកដល់សម័យអាណានិគមបារាំង ទើបមានអគារធំៗធ្វើពីឥដ្ឋនិងស៊ីម៉ង់។



ព្រះបាទពញាយ៉ាត(១៤២១?-១៤៦៣) បានវាយទ័ពសៀម រំដោះក្រុងអង្គរបានមកវិញ តែអាណាខេត្តខ្មែរមួយចំនួនខាងលិចនិងខាងជើង បានក្លាយទៅជារបស់សៀម និងលាវទៅហើយ។ អង្គរលែងជាចំណុចកណ្ដាលនៃព្រះរាជាណាចក្រខ្មែរទៀតហើយ។ នៅឆ្នាំ១៤៣១ ព្រះអង្គបានចាកចោលក្រុងអង្គរ ហើយយាងមកតាំងរាជធានីថ្មីនៅភាគខាងត្បូងនៃប្រទេសវិញ។

នៅគ្រាដំបូង ព្រះអង្គទ្រង់យាងមកតាំងរាជធានីនៅទួលបាសាន (សព្វថ្ងៃក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម) តាមដងទន្លេមេគង្គ ខាងលើចតុមុខ។ កន្លែងនោះស្ថិតនៅក្នុងតំបន់មួយ ដែលនៅឆ្ងាយពីសត្រូវផង និងសំបូរដោយភោគទ្រព្យសំរាប់ព្រះរាជនគរផង។ ប៉ុន្តែនៅឆ្នាំនោះ ទឹកទន្លេមេគង្គឡើងជន់ខ្លាំងណាស់ ហើយធ្វើអោយលិចលង់រាជធានីថ្មីនេះអស់មួយភាគ។ ព្រះមហាក្សត្រក៏បញ្ជាមនុស្សមួយក្រុមអោយទៅស្វែងរកទីកន្លែងមួយផ្សេងទៀត ដែលខ្ពស់មិនលិចទឹកជំនន់ទន្លេមេគង្គ នៅរដូវវស្សា។ ក្រុមនោះបានចេញទៅធ្វើការសង្កេតពិនិត្យទីតាំងផ្សេងៗ រួចក៏សំរេចជ្រើសរើសយកចតុមុខ សំរាប់តាំងរាជធានីថ្មី។ ចតុមុខ រឺភ្នំពេញស្ថិតនៅត្រង់ទន្លេបួនមុខ និងហ៊ុមព័ទ្ធទៅដោយវាលសំបូរជីជាតិ។ ភ្លាមៗនោះ ការកសាងក៏បានចាប់ផ្ដើមឡើង។ ឯព្រះមហាក្សត្រទ្រង់បន្តគង់នៅទួលបាសាន រហូតដល់ពេលរាជធានីថ្មីបានសាងរួចរាល់នៅឆ្នាំ១៤៣៤។



# ចតុមុខ-រាជធានីថ្មីរបស់ព្រះបាទពញាយ៉ាត
## ចាប់ពីឆ្នាំ១៤៣៤

**ទីស្ថិតដ៏ល្អសំរាប់តាំងរាជធានី !**
ភ្នំពេញស្ថិតនៅត្រង់កន្លែងទន្លេប្រសព្វមុខ៤។ ទន្លេទាំងនោះធំៗហើយអាចអោយនាវាបើកបាន។ ដូចនោះ ភ្នំពេញអាចត្រួតពិនិត្យជំនួញតាមទន្លេដែលមានធ្វើជាមួយប្រទេសលាវ តំបន់បឹងទន្លេសាប និង តំបន់ដីសណ្តទន្លេមេគង្គ។

នៅឆ្នាំ១៤៣៤ ព្រះបាទពញាយ៉ាត និងរាជបរិពារបានចាកចោលព្រះរាជវាំងនៅទួលបាសាន។ ទ្រង់យាងចុះតាមទន្លេមេគង្គ មកគង់នៅរាជធានីថ្មីស្ថិតនៅត្រង់ទីក្រុងភ្នំពេញបច្ចុប្បន្ន ដែលគេហៅថាក្រុងចតុមុខ តាំងពីពេលនោះមក។

### ▶ ភ្នំពេញស្ថាបនាឡើងយ៉ាងរហ័ស

នៅចតុមុខ ព្រះបាទពញាយ៉ាតកសាងរាជធានីថ្មីបានរួចរាល់យ៉ាងឆាប់រហ័ស។ ទ្រង់បានអោយគេសាងសង់វាំងមួយលើដីទួល ធ្វើកំពែង និងតីរវិថី គឺផ្លូវបិតនៅបណ្តោយតាមឆ្នេរទន្លេ។ ដោយយកគំរូតាមប្រពៃណីព្រះរាជាសម័យអង្គរ ទ្រង់បានបញ្ជាអោយគេជីកបណ្តាញផ្លូវទឹកសព្វគ្រប់ទាំងអស់ : ព្រែកពាមផ្លុងនាំទឹកទន្លេបញ្ចូលមកក្នុងក្រុង ឯព្រែកតាកែវ ព្រែកអូរគ និងព្រែកពោង-ពាយ ដែលមានទឹកពោរពេញ ហ៊ុមព័ទ្ធទីក្រុងថ្មីនេះ។ ជាបន្តបន្ទាប់ ពួកមន្ត្រីនិងអ្នកក្រុងសង់ផ្ទះសំបែងតាមលទ្ធភាពរបស់ខ្លួន នៅខាងក្នុងបរិវេណរាជធានីនេះ។ នៅប៉ែកខាងលិច ស្រែថ្មីៗដែលប្រាកដជាបានទទួលការស្រោចស្រពតាមរយៈការបញ្ចូលទឹក ចាប់ផ្តើមលាតសន្ធឹងឆ្ងាយទៅៗ។ ព្រះរាជាបញ្ជាអោយកែលំអភ្នំរបស់ដូនពេញ : លើកដីពង្រីកភ្នំអោយធំនិងខ្ពស់ជាងមុន សង់វិហារដូនពេញឡើងវិញ រៀបចំជាទីលានក្រាលថ្ម និងកសាងចេតិយធំមួយផងនៅលើកំពូលភ្នំ។ ទ្រង់បញ្ជាអោយទៅយកពីក្រុងអង្គរនូវរូបគោថ្មមកតាំងលំអ និងព្រះពុទ្ធបដិមាលង្ហិនមកតំកល់ក្នុងចេតិយនៅជាន់ក្រោម ព្រះពុទ្ធបដិមារបស់ដូនពេញតំកល់នៅជាន់ខាងលើ។ ឯទន្លេច្រាបឈាមក៏បានប្តូរឈ្មោះទៅជាទន្លេចតុមុខវិញ។







### រឿងព្រេងពីភ្នំដូនពេញ

មានដូនចាស់ម្នាក់ឈ្មោះ ពេញ បានសាងសង់ផ្ទះមួយ នាត្រើយខាងលិចទន្លេ ក្បែរទួលខ្ពស់មួយ។ ថ្ងៃមួយនោះ ក្នុងរដូវវស្សា ពេលទឹកជំនន់ឡើងខ្លាំង ❶ ដូននោះប្រទះឃើញដើមគគីរមួយធំអណ្តែតរសាត់តាមទឹកក្នុងទន្លេ។ គាត់បានជិះទូកមួយរួមជាមួយអ្នកជិតខាង ទៅអូសទាញដើមគគីរនោះយកមកដល់មាត់ច្រាំង ❷។ នៅក្នុងប្រហោងដើមគគីរនោះ គេប្រទះឃើញព្រះពុទ្ធបដិមាលង្ហិន៤អង្គ និងបដិមាថ្មមួយអង្គទៀត ❸។ បន្ទាប់មក អ្នកភូមិបាននាំគ្នាលើកដីពូនទួលនោះអោយខ្ពស់ឡើងទៀត រហូតក្លាយជាភ្នំតូចមួយ។ នៅលើកំពូលភ្នំ គេសង់វិហារតូចមួយពីឈើគគីរអណ្តែតទឹកនោះ មានដំបូលប្រក់ស្បូវភ្លាំង ដើម្បីដាក់ព្រះពុទ្ធរូប។ គេតំកល់បដិមាថ្មនៅជើងភ្នំ ប៉ែកខាងឦសានព្រះវិហារ។ គេថ្វាយព្រះនាមថា «អ្នកតាព្រះចៅ»រឺ «លោកតាព្រះចៅ»។ បដិមាទាំងនោះមានមហិទ្ធិរិទ្ធិណាស់ ហើយអាចជួយអោយសំរេចការបន់ស្រន់របស់អ្នកស្រុកបាន។ ភ្នំនោះក៏មានឈ្មោះហៅថា «ភ្នំដូនពេញ» ដែលក្រោយមកគេហៅថា «ភ្នំពេញ»។




**ទីក្រុងភ្នំពេញនៅស.វ.ទី១៥**

### ▶ ភ្នំពេញរីកចំរើនយ៉ាងលឿន

ភ្នំពេញជាទីក្រុងថ្មី ដែលរីកចំរើនយ៉ាងឆាប់រហ័ស។ មិនយូរប៉ុន្មានរាជធានីនេះមានវត្តអារាមជាច្រើន និងមានមនុស្សមករស់នៅយ៉ាងកុះករ។ ការបង្កើតទីក្រុងនេះ បានបើកសករាជថ្មីនៃការលូតលាស់ថ្កុំថ្កើង និងភាពសុខសាន្ត។ ឈ្មួញចិននិងជ្វាចូលមកតាំងលំនៅជាប់លាប់ដើម្បីរកស៊ីលក់ដូរ។ អ្នកប្រាជ្ញនិងអ្នកមានចំណេះដឹងនៅអាស៊ីអាគ្នេយ៍ចូលមកជាច្រើន ទាក់ទាញដោយសារកេរ្តិ៍ឈ្មោះល្បីល្បាញរបស់វត្តអារាមធំៗខាងព្រះពុទ្ធសាសនា និងព្រះសង្ឃពហុស្សុតជាច្រើន។ នគរចិន យួន ចាម ជ្វា នាំគ្រឿងបណ្ណាការមកក្រាបទូលថ្វាយសូមចងមេត្រី។ ក្នុងមួយរយៈកាលចាប់ពីពេលនោះមក ព្រះនគរកម្ពុជាក៏មានឈ្មោះល្បីរន្ទឺឡើងវិញ បន្ទាប់ពីការធ្លាក់ចុះខ្សោយដោយសារការបែកក្រុងអង្គរ។

**សាកល្បងរកចំលើយ**

ដើម្បីការពារក្រុងភ្នំពេញ ព្រះបាទពញាយ៉ាតបាន
ក-សង់កំពែងអំពីឥដ្ឋ ?
ខ-ដាំឫស្សីធ្វើជារបង ?
គ-ជីកព្រែក និងលើកដីជាកំពែង ?

ចំលើយ : ទំព័រ៤៤

# នាយកន-ស្តេចជ្រែករាជ្យ

## ១៥១២-១៥២៥

### បន្តពីព្រះពញាយ៉ាត

- មានស្តេចនារាយណ៍រាជា : ១៤៦៣-១៤៦៩
- មានស្តេចបីអង្គទាស់គ្នា :
  - ស្រីរាជា : ១៤៦៩-១៤៨៥
  - ស្រីសុរិយោទ័យ : ១៤៧៧-១៤៨៥
  - ធម្មរាជា : ១៤៧៨-១៥០៤



ព្រះខាន់រាជ្យ រឺ ព្រះខាន់ជ័យ

### សំណាញ់និងមេថា

ព្រះបាទ ស្រីសុគន្ធបទ លើក នាងពៅ ហៅ ស ជាស្នំឯក។ នាងមានឥទ្ធិពលខ្លាំងទៅលើព្រះរាជារហូតដល់ទ្រង់អោយប្តូរឈ្មោះ «បាសាន» ទៅជា «ស្រីសឈរ» ដែលក្លាយទៅជា «ស្រីសន្ធរ» រហូតមកដល់សព្វថ្ងៃ(ស្រុកមួយក្នុងខេត្តកំពង់ចាម)។

ស្តេចច្រើនអង្គបានសោយរាជ្យបន្តពីព្រះបាទពញាយ៉ាត។ ខ្មែរវាយរំដោះយកបានខេត្តដែលសៀមបានដណ្តើមយកទៅ។ ប៉ុន្តែដោយមានទំនាស់ក្នុងរាជវង្ស ខេត្តទាំងនោះបានត្រូវបាត់បង់សាជាថ្មីទៅវិញ។ ព្រះបាទស្រីសុគន្ធបទ (១៥០៤-១៥១២) ដែលស្នងរាជ្យពីបិតានាមធម្មរាជា បានត្រូវនាយកនធ្វើគុត។



ស្តេចកនទទួលអ្នកជំនួញមកពីស្រុកចិន។

### ▶ នាយកនជ្រែករាជ្យ

នាយកនជាកូនរបស់ទាសករម្នាក់ក្នុងចំណោមពួកបរិវារស្តេច។ បងស្រីនាយកន ឈ្មោះនាងពៅ ហៅ ស មានរូបសម្ផស្សស្រស់ស្អាតណាស់។ នាងបានឡើងជាស្នំឯករបស់ព្រះបាទស្រីសុគន្ធបទ ដែលយាងទៅគង់មួយរយៈនៅឯទួលបាសាន។ គ្រួសារនាងក៏បានបុណ្យស័ក្តិ ហើយកនជាប្អូនប្រុសនាងក៏បានធ្វើជាមន្ត្រីធំ។ ថ្ងៃមួយ ព្រះរាជាទ្រង់សុបិនអាក្រក់ ដែលហោរាកាត់ថា នាយកនចង់ជ្រែករាជ្យ។ ទ្រង់រៀបចំផែនការយកនាយកនទៅសំលាប់ក្នុងទឹក ពេលទៅក្រសាលបឹងបង់សំណាញ់។ ប៉ុន្តែនាយកន ដែលដឹងផែនការនេះតាមរយៈបងស្រី បានគេចខ្លួនរួច ហើយទៅបំបះបំបោររាស្ត្រ។ នាយកននាំទ័ពជាច្រើនវាយយកបានទីក្រុងភ្នំពេញ រួចតាមទៅធ្វើគុតព្រះរាជាទៀត។ ប៉ុន្តែព្រាហ្មណ៍ម្នាក់បានយកព្រះខាន់រាជ្យ ដែលជានិមិត្តរូបនៃរាជាធិបតេយ្យ ទៅលាក់ទុក។ នាយកនអោយគេធ្វើព្រះខាន់រាជ្យក្លែងក្លាយ ហើយឡើងសោយរាជ្យ (គ.ស.១៥១២)។ បន្ទាប់មក ដើម្បីបង្ហាញរិទ្ធិអំណាចរបស់ខ្លួន ស្តេចកនបានកសាងរាជធានីថ្មីនៅភូមិស្រឡប់ (ក្នុងស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម សព្វថ្ងៃ) ហើយអោយឈ្មោះថា ក្រុងស្រឡប់ពិជ័យព្រៃនគរ។

នៅសម័យនោះ គ្រីស្តូបកូឡុំ រកឃើញដែនដីអាមេរិច ។

### ▶ ចំបាំងរវាងនាយកន និងចន្ទរាជា រឺអង្គចន្ទ

ថ្វីត្បិតតែស្តេចកន ដែលគេនិយាយថាមានមហិទ្ធិរិទ្ធិអស្ចារ្យនោះ ជាអ្នកដណ្តើមរាជសម្បត្តិក៏ដោយ ស្តេចកនក៏ជាព្រះរាជាដ៏ល្អមួយអង្គចំពោះរាស្ត្រដែរ។ ស្តេចកនកាត់បន្ថយពន្ធដារ។ ប្រទេសជាតិស្គាល់សុខសន្តិភាព។ មានបរទេសជាច្រើនចូលមកនគរខ្មែរ ដើម្បីរកស៊ីធ្វើជំនួញ។ នោះគឺជាសម័យដ៏ត្រចះត្រចង់មួយ។ ប៉ុន្តែព្រះអង្គចន្ទ អនុជរបស់ព្រះបាទស្រីសុគន្ធបទ ដែលបានភៀសខ្លួនទៅស្រុកសៀម បានយាងត្រលប់មកវិញ។ ទ្រង់បានរៀបចំការតស៊ូប្រឆាំងនិងស្តេចកនជ្រែករាជ្យ។ ការតស៊ូរីកចំរើនយ៉ាងរហ័ស ដោយចាប់ផ្តើមចេញពីអាណាខេត្តខាងលិច។ តាមឿង (ខ្លះថាតាពេជ) បានសំលាប់ចៅហ្វាយស្រុក បញ្ចុះបញ្ចូលរាស្ត្រនិងពលទាហានអោយចូលខាងព្រះអង្គចន្ទ។ ក្សត្រអង្គនេះជាចៅរបស់ព្រះបាទពញាយ៉ាត ដែលជាស្ថាបនិកក្រុងចតុមុខ ដូចនេះទ្រង់ជារជ្ជទាយាទស្របច្បាប់។ តាមសំណូមពរពីរាជវង្សនិងមន្ត្រី ទ្រង់យល់ព្រមឡើងគ្រងរាជ្យបណ្តោះអាសន្ននៅឆ្នាំ១៥១៦។ ប៉ុន្តែនាយកនក៏មានប្រជាប្រិយភាពដែរ។ ប្រជារាស្ត្រមានការស្ទាក់ស្ទើរ។ ការប្រយុទ្ធគ្នាអូសបន្លាយអស់រយៈពេល៩ឆ្នាំ។ គូប្រកួតទាំងពីរទទួលស្គាល់តំលៃគ្នាទៅវិញទៅមក ហើយខិតខំធ្វើយ៉ាងណាអោយអ្នកស្រុករងទុក្ខវេទនាតិចតួចបំផុត។ នៅឆ្នាំ១៥២៥ ព្រះអង្គចន្ទបានទទួលជ័យជំនះ។ ស្តេចកនត្រូវគេចាប់បាន រួចត្រូវគេពិឃាតទៅ។

### សារ ដែលស្តេចកនថ្វាយទៅព្រះអង្គចន្ទសុំផ្អាកចំបាំង

«...ប៉ុន្តែដោយរដូវវស្សានឹងចូលមកដល់ និងដោយមានការចាំបាច់ទុកពេលអោយកសិករធ្វើស្រែសិន ខ្ញុំសូមស្នើផ្អាកចំបាំងគ្នាក្នុងរដូវនេះក្នុងល័ក្ខខ័ណ្ឌដែលគ្មាននរណានៃពួកយើងឆ្លៀតយកចំណេញពីការផ្អាកចំបាំងនេះ ដើម្បីលួចដណ្តើមយកអាណាខេត្តរបស់អ្នកម្ខាងទៀតឡើយ...»

### ហើយបន្ទាប់មកព្រះអង្គចន្ទឆ្លើយតប

«បើខ្ញុំត្រូវចាញ់ ហើយស្លាប់ក្នុងសមរភូមិ នោះពេលវេលានឹងមកដល់ហើយដែលរាស្ត្រត្រូវលើកនាយកនជាស្តេច ប៉ុន្តែក្នុងពេលនេះ សុំអោយគេហៅតាមឋានៈដែលវាមានមុនការបះបោរ គឺ "នាយកន រាជបំរើព្រះមហាក្សត្រ"»

រូបតំណាងតាឃ្លាំងមឿង នៅស្រុកបាកាន ខេត្តពោធិ៍សាត់



# ចន្ទរាជា រីអង្គចន្ទទី១–ស្ថាបនិកក្រុងលង្វែក

## ១៥១៦–១៥៦៦

**សាកល្បងរកចំលើយ**

បច្ចុប្បន្ននេះ លង្វែកស្ថិតនៅក្នុងខេត្ត
ក–កំពង់ឆ្នាំង ?
ខ–កណ្តាល ?
គ–កំពង់ស្ពឺ ?

ចំលើយ : ទំព័រ៤៤

**ហេតុអ្វីក៏មានខេត្តឈ្មោះសៀមរាប ?**

ពីព្រោះនៅក្នុងការប្រយុទ្ធមួយដ៏ខ្លាំងក្លាកើតឡើងនៅតំបន់នោះ ក្នុងសមរភូមិជិតក្រុងអង្គរ ទ័ពសៀមបានត្រូវកំទេចរាប ដោយកងទ័ពខ្មែរ។

កងទ័ពសៀមបរាជ័យយ៉ាងធ្ងន់ធ្ងរនៅជិតក្រុងអង្គរ។

**បន្ទាប់ពីបានកំចាត់ស្តេចកនហើយនោះ ព្រះចន្ទរាជាបានឡើងសោយរាជ្យ។ ទ្រង់បានដេញពួកសៀមឈ្លានពាន និងថែមទាំងវាយដណ្តើមយកបានដែនដីខ្លះមកអោយខ្មែរវិញផង។ ឯស្នាព្រះហស្តធំមួយទៀត គឺការកសាងក្រុងលង្វែក។**

### ▶ ជ័យជំនះលើសៀម

ស្តេចសៀមនៅស្ងប់ស្ងាត់យ៉ាងចំលែក ហើយពុំបានបញ្ជូនកងទ័ពមកធ្វើអន្តរាគមន៍ក្នុងចំបាំងរវាងនាយកននឹងចន្ទរាជាទេ។ ប៉ុន្តែនៅឯរាជវាំងស្តេចសៀម ដែលព្រះអង្គម្ចាស់ចន្ទរាជាបានភៀសខ្លួនទៅគង់នៅមួយរយៈនោះ ស្តេចសៀមនៅតែមានបំណងពង្រីកអំណាចមកលើអាណាចក្រខ្មែរទៀត។ ស្តេចសៀមបានទាមទារអោយខ្មែរយកសួយសារអាករនិងដំរីសទៅថ្វាយ។ ព្រះបាទចន្ទរាជាមិនយល់ព្រម។ សៀមក៏បញ្ជូនកងទ័ពមករាតត្បាតខេត្តអង្គរ។ កងទ័ពខ្មែរដែលមានការរឹកហាត់ល្អបានវាយកំទេចទ័ពសៀមនៅជិតក្រុងអង្គរ។ ខ្មែរចាប់បានឈ្លើយសឹកប្រមាណ ១០ ០០០នាក់។ ស្តេចសៀមសងសឹកវិញ ដោយលើកព្រះអង្គម្ចាស់ពញាអុង អោយធ្វើជាស្តេចខ្មែរ។ ពញាអុងជាក្សត្រខ្មែរ ដែលបានប្រសូតឡើង និងទទួលការអប់រំនៅស្រុកសៀម ហើយស្តេចសៀមបានទុកព្រះអង្គម្ចាស់ជាកូនចិញ្ចឹម។ ស្តេចសៀមប្រគល់ទ័ពអោយពញាអុងបញ្ជា។ ទ័ពសៀមវាយលុកចូលតាមផ្លូវគោកនិងសមុទ្រ ប៉ុន្តែត្រូវទ័ពខ្មែរវាយអោយថយទៅវិញ។ ព្រះអង្គម្ចាស់ពញាអុងបានបាត់បង់ជីវិតលើខ្នងដំរី ដោយត្រូវនឹងព្រួញ។ ក្រោយមកទៀត





ទ័ពខ្មែរបានវាយបកត្រលប់ទៅវិញជាច្រើនលើក ហើយនៅក្នុងឆ្នាំ១៥៥៧ បានទំលាយចូលរហូតដល់ជាយក្រុងអយុធ្យាទៀតផង។





**ផែនទីបន្ទាយលង្វែក**

- កំពែង និងគូ
- ទំនប់
- ផ្លូវ

### ▶ ការកសាងក្រុងលង្វែក (១៥២៧–១៥២៩)

ដូចព្រះរាជាខ្មែរមុនៗដែរ ព្រះបាទចន្ទរាជាបានស្ថាបនារាជធានីថ្មីមួយ គឺក្រុងលង្វែកស្ថិតនៅចំងាយប្រមាណ ៧០គមពីទីក្រុងភ្នំពេញ លើត្រើយខាងលិចនៃទន្លេសាប ជិតច្រកផ្នែកទ្រូចូលទៅបឹងទន្លេសាប។ បន្ទាយលង្វែកចាប់កសាងឡើងនៅឆ្នាំ១៥២៧ ជាបន្ទាយមួយរឹងមាំណាស់ មានដាំដើមឫស្សីធ្វើជារបងយ៉ាងក្រាស់ព័ទ្ធជុំវិញសំរាប់ជារបាំងការពារ។ ព្រះបាទចន្ទរាជាជាមហាក្សត្រ ដែលមានជំនឿយ៉ាងខ្លាំងក្លាទៅលើព្រះពុទ្ធសាសនា និងទៅលើពួកព្រាហ្មណ៍។ ព្រះអង្គកសាងសំណង់បំរើសាសនាជាច្រើន។ ទ្រង់អោយសង់វត្តត្រឡែងកែង ដែលតំកល់ព្រះពុទ្ធរូបត្រឡែងកែង គឺព្រះពុទ្ធរូប៤អង្គគង់ឈរទល់ខ្នងគ្នា ហើយបែរព្រះភក្ត្រទៅទិសទាំង៤។ ទ្រង់សាងរូបព្រះគោ ព្រះកែវ និងបដិមាខាងព្រាហ្មណ៍សាសនាដទៃទៀត។ នៅឧដុង្គ ព្រះអង្គអោយសង់វត្តមួយនៅខាងកើត «ភ្នំព្រះរាជទ្រព្យ» ហៅថាវត្តបឋមកើ្ត។ នៅលើភ្នំ ដែលលេចឡើងត្រដែតខ្ពស់ផុតពីលើទីក្រុង ទ្រង់បានសាងព្រះពុទ្ធរូបអង្គធំមួយព្រះអង្គ។ ទ្រង់បានអោយជីកស្រះទឹកផងដែរ។ ក្នុងការខិតខំពង្រីកសេដ្ឋកិច្ចជាតិ ព្រះអង្គបានរៀបចំប្រព័ន្ធប្រឡាយទឹកចេញពីបឹងមួយសំរាប់យកទឹកទៅបញ្ចូលស្រែ បានពង្រីកការជីកយករ៉ែដែក និងអោយកាប់ឆ្ការព្រៃឈើដើម្បីវាតដីថ្មីសំរាប់ធ្វើស្រែ។ ព្រះបាទចន្ទរាជាជាមហាក្សត្រសំខាន់ជាងគេនៅសតវត្សទី១៦។ រជ្ជកាលរបស់ទ្រង់ជារយៈពេលមួយសំបូរសប្បាយក្នុងប្រវត្តិសាស្ត្រកម្ពុជា។ នៅជំនាន់នោះ មានភ្ញៀវមកពីអឺរ៉ុបបានមកដល់កម្ពុជា គឺពួកប័ទុយកាល់និងអេស្ប៉ាញ។

**រឿងទុំទាវ**

រឿងទុំទាវ សរសេរជាកាព្យពាក្យប្រាំពីរ ពីដើមដល់ចប់ ដោយព្រះភិក្ខុសោម ក្នុង គ.ស.១៩១៥ រជ្ជកាលព្រះបាទស៊ីសុវត្ថិ។ រឿងនេះនិទានពីស្នេហាភក្តីរវាងម៉ឺនឯក ហៅទុំ និងនាងទាវ ដែលកើតមានឡើងនៅក្នុងសម័យលង្វែក។

# បរមរាជា-ឈ្នះសៀម និងលាវ

## ១៥៦៦-១៥៧៦




លោកសង្ឃចារសាស្ត្រា។ វត្តអារាមជាកន្លែងបង្រៀនវប្បធម៌ និងចំណេះវិជ្ជា។

ព្រះរាជាណាចក្រកម្ពុជានៅមានមហិទ្ធិរិទ្ធិខ្លាំងពូកែ និងសំបូរសប្បាយនៅឡើយ។ ព្រះបាទបរមរាជា ដែលជាបុត្រានិងជាអ្នកសោយរាជ្យបន្តពីព្រះបាទចន្ទរាជា បានធ្វើចំបាំងឈ្នះសៀម ហើយក្រោយមកឈ្នះលាវពីរលើកទៀតផង។

### ▶ ជ័យជំនះលើទ័ពសៀម

ព្រះបាទបរមរាជា បានធ្វើចំបាំងវាយលុកទៅលើនគរសៀម ដើម្បីរំដោះយកអាណាខេត្តខ្មែរ ដែលសៀមបានដណ្ដើមយកទៅ។ ដោយចង់នៅក្បែរកន្លែងរៀបចំសង្គ្រាម ព្រះរាជាបានយាងទៅគង់នៅកំពង់ក្រសាំងជិតអង្គរ នៅឆ្នាំ១៥៧០។ ព្រះអង្គក៏បានយាងទៅអតីតរាជធានីអង្គរ ព្រមទាំងបានទស្សនាប្រាសាទបាយ័ន ដែលបានត្រូវសាងសង់ឡើងកាលពីពាសតវត្សមុន ដោយព្រះបាទជ័យវរ្ម័នទី៧ និងដែលនៅពេលនោះមានព្រៃដុះទ្រុបទ្រុលទៅហើយ។ ដោយកោតសរសើរស្នាព្រះហស្តរបស់បុព្វបុរស ព្រះអង្គអោយគេជួសជុលនិងរៀបចំឡើងវិញ។ កងទ័ពខ្មែរ ដែលវាយលុកចូលនគរសៀម បានទទួលជ័យជំនះយកបានខេត្តនគររាជសីមាមកវិញ ហើយដាក់មន្ត្រីខ្មែរម្នាក់អោយត្រួតត្រា។ ឯជនជាតិភូមា ដែលវាយយកបានក្រុងអយុធ្យាកាលពីឆ្នាំ១៥៦៤ នៅតែគាបសង្កត់សៀមបន្តទៀត។ ដោយត្រូវភូមានិងខ្មែរវាយគាបខ្លាំងពេក សៀមបានសុំយកខ្មែរជាមិត្ត ហើយចុះសន្ធិសញ្ញាចងសម្ព័ន្ធភាពជាមួយខ្មែរនៅឆ្នាំ១៥៧៤ ដោយព្រមប្រគល់ខេត្តនគររាជសីមា ចន្ទបុរី និងបស្ចិមបុរីមកខ្មែរវិញ។ ក្នុងពេលជាង១០ឆ្នាំបន្ទាប់មក ខ្មែរនិងសៀមពុំមានធ្វើចំបាំងនឹងគ្នាឡើយ។

#### សម្ព័ន្ធភាពខ្មែរ-សៀម ឆ្នាំ១៥៧៤

« ព្រះមហាក្សត្រទាំងពីរនគរបានធ្វើសន្ធិសញ្ញាចងព្រះរាជមេត្រីថា បើមានសឹកសង្គ្រាមពីប្រទេសក្រៅក្ដី ក្នុងក្ដី ត្រូវជួយគ្នាអោយអស់ពីហឫទ័យទាំងសងខាង ហើយសង់ព្រំព្រះរាជសីមា...។ »

(ឯកសារមហាបុរស)

នៅសម័យនោះ ពួកប៉័ទុយកាល់និងអេស្ប៉ាញបានចូលមកនៅកោះស៊ូម៉ាត្រា ភីលីពីន ម៉ាកាវ និងនៅជប៉ុន។



### ▶ ជ័យជំនះលើទ័ពលាវ : ប្រជល់ដំរី

នៅគ.ស.១៥៧២ ស្ដេចលាវបញ្ជូនដំរីមួយកំពស់៨ហត្ថ (៤ម) ទាហាន ១ ០០០នាក់ និងមន្ត្រី២នាក់មកនគរខ្មែរ។ ស្ដេចលាវស្នើសុំភ្នាល់ប្រជល់ដំរីនោះនឹងដំរីខ្លាំងបំផុតរបស់ខ្មែរ។ ឯខសន្យា គឺថាបើដំរីនគរណាចាញ់ នគរនោះត្រូវចំណុះនគរដែលមានដំរីឈ្នះ។ ការប្រជល់ដំរីប្រព្រឹត្តទៅនៅក្បែរក្រុងលង្វែក។ ដំរីខ្មែរកំពស់៧ហត្ថ (៣,៥ម) តែក្លាហានណាស់ ហើយឈ្នះដំរីលាវ។ ព្រះបាទបរមរាជាចាប់យកពលលាវទាំង ១ ០០០នាក់ ទុកជាឈ្លើយសឹក ហើយបញ្ជូនតែមន្ត្រី២នាក់នោះត្រលប់ទៅវិញ។ បរាជ័យនេះធ្វើអោយស្ដេចលាវអាប់មុខ រួចក៏ចងគំនុំសងសឹក។ ស្ដេចលាវលើកទ័ពចូលវាយនគរខ្មែរ។ ទ័ពលាវមានប្រមាណ ៥០ ០០០នាក់ ចុះតាមទន្លេមេគង្គនិងប្រមាណ ៧០ ០០០នាក់ទៀតចូលមកតាមផ្លូវគោក។ ទ័ពលាវបរាជ័យទាំងស្រុង។ ខ្មែរចាប់បានឈ្លើយសឹកជាច្រើន។ ស្ដេចលាវបានរត់គេចខ្លួនរួច។ នៅឆ្នាំ១៥៧៤ ស្ដេចលាវលើកទ័ពមកវាយនគរខ្មែរជាលើកទី២ តែត្រូវបរាជ័យទៀត។ បន្ទាប់មកព្រះរាជាណាចក្រខ្មែរបានរស់នៅក្នុងសុខសន្តិភាពឡើងវិញ។ ប៉ុន្តែមិនយូរប៉ុន្មាន សៀមជាសត្រូវចាស់ក៏បានចាប់ផ្ដើមធ្វើសង្គ្រាមជាថ្មីទៀតនៅឆ្នាំ១៥៨៨។



#### ជាប្រទេសខ្លាំងពូកែនៅឡើយ

នៅក្នុងរជ្ជកាលព្រះបាទចន្ទរាជា និងព្រះបាទបរមរាជា ដែលជាព្រះរាជបុត្រាស្នងរាជ្យបន្តពីព្រះអង្គ នគរខ្មែរនៅជាប្រទេសខ្លាំងពូកែជាងគេនៅតំបន់អាស៊ីអាគ្នេយ៍។

#### សំណាញ់ដឹងទេថា

បារាយណ៍ ដែលជាឈ្មោះរបស់ស្រុកមួយក្នុងខេត្តកំពង់ធំសព្វថ្ងៃនេះ ក្លាយមកពីពាក្យ «បានលាវ ផៀងរ៉ាយ» (នៅសល់តែពាក្យដើម បា និងពាក្យចុង រ៉ាយ) ព្រោះព្រះបាទបរមរាជា បានអនុញ្ញាតអោយឈ្លើយសឹកលាវមកពីស្រុក «ផៀងរ៉ាយ» រស់នៅ។

ដំរីខ្មែរតូច តែក្លាហានណាស់ ហើយផល់ឈ្នះដំរីលាវ។

# អ្នកផ្សាយសាសនា ឈ្មួញ និងទាហានអឺរ៉ុប

## សតវត្សទី១៦



ពួកឈ្មួញអឺរ៉ុប
មកដល់ស្រុកខ្មែរ។

**ព្រះបាទសត្ថាទី១ឡើងគ្រងរាជ្យក្នុងឆ្នាំ១៥៧៦ បន្តពីបិតាព្រះនាមបរមរាជា។ សម័យនោះ កម្ពុជាទទួលភ្ញៀវមកពីអឺរ៉ុបជាច្រើន។ អស់មួយសតវត្សមកហើយដែលអឺរ៉ុបបានចេញទៅរុករកពិភពលោក ដោយប្រើសំពៅធំៗនិងកាំភ្លើង។**

### ▶ អ្នកផ្សាយសាសនា និងពួកឈ្មួញ

អឺរ៉ុបបានធ្វើសញ្ជ័យទៅលើទ្វីបអាមេរិច។ នៅទ្វីបអាព្រិចនិងអាស៊ី គេបានបញ្ជូនអ្នកផ្សាយសាសនាអោយមកផ្សព្វផ្សាយសាសនាព្រះយេស៊ូ។ តាំងពីចុងរាជ្យព្រះបាទចន្ទរាជាមកម្ល៉េះ អ្នកផ្សាយសាសនាជាតិប័ទុយ-កាល់និងអេស្ប៉ាញបានមកដល់ក្រុងលង្វែកហើយ។ ក្នុងរាជ្យព្រះបាទសត្ថាទី១ (១៥៧៦–១៥៨៦) នៅប្រទេសកម្ពុជា ជនជាតិខ្មែរព្រមទទួលអ្នកផ្សាយសាសនាគ្រិស្ត។ ពួកគេមានសិទ្ធិផ្សព្វផ្សាយសាសនារបស់គេ និងអាចកសាងវិហារគ្រិស្តនៅសព្វទីកន្លែង។ ឯរាស្ត្រខ្មែរមានសិទ្ធិជឿក៏បាន មិនជឿក៏បាន។ ប៉ុន្តែធម្មទេសនារបស់ពួកគេបានជោគជ័យតិចតួចណាស់ ព្រោះខ្មែរមានជំនឿមោះមុតទៅលើព្រះពុទ្ធសាសនាជាយូរមកហើយ។ ព្រមគ្នាជាមួយពួកអ្នកផ្សព្វផ្សាយសាសនាគ្រិស្ត គេក៏បានឃើញពួកឈ្មួញចូលមកដែរ។ នៅសតវត្សទី១៦ កម្ពុជាជាប្រទេសសំបូររុងរឿង។ ឈ្មួញអឺរ៉ុបចូលមករកស៊ីច្រើន ៖ គេបង្កើតសាខាគ្រឹះស្ថានជំនួញ លក់កាំភ្លើងតូចធំ គ្រាប់រំសេវ... ជាថ្នូរពួកគេទិញគ្រឿងទេស ត្បូងមានតំលៃ ភ្លុក ខ្លឹមចន្ទន៍... សំរាប់នាំចេញទៅវិញ។

### ▶ ពួកទាហាន និងពួកអ្នកផ្សងព្រេង

មានទាហាននិងអ្នកផ្សងព្រេងចូលមកជាច្រើន។ អ្នកខ្លះស្ម័គ្រចិត្តបំរើព្រះមហាក្សត្រ ៖ អ្នកដែលគេស្គាល់ច្រើនគឺ លោក ប្លសឺ ដឺ អ៊ែណង់ និង ដ្យេក វេឡូស្ទ ដែលព្រះរាជាសព្វព្រះហឫទ័យយ៉ាងខ្លាំង។ ព្រះអង្គទ្រង់ប្រទានកិត្តិយសអោយគេធ្វើជាអង្គរក្សព្រះអង្គ និងអោយគេបានរៀបអាពាហ៍ពិពាហ៍ជាមួយម្ចាស់ក្សត្រីទៀតផង។ ជនបរទេសខ្លះបានចូលរួមក្នុងព្រឹត្តិការណ៍នានាក្នុងស្រុក ខ្លះទៀតបានប្រទះព្រឹត្តិការណ៍ប្លែកៗក្នុងចំបាំងជាមួយសៀម។ អ្នកផ្សាយសាសនាខ្លះបានសរសេរសៀវភៅ ដែលជួនកាលមានប្រយោជន៍ណាស់សំរាប់ប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ អ្នកខ្លះទៅមើលប្រាសាទអង្គរ ដែលព្រះបាទចន្ទរាជាបានរកឃើញឡើងវិញ។ បន្ទាប់មកព្រះបាទសត្ថាទី១ក៏បានជួសជុលប្រាង្គធំនៅប្រាសាទអង្គរវត្ត ហើយធ្វើសិលាចារឹកឧទ្ទិសថ្វាយព្រះពុទ្ធទៀតផង។

### ? សាកល្បងរកចំលើយ

ព្រះបាទសត្ថាទី១ បានទទួលអ្នកផ្សាយសាសនាគ្រិស្ត ដោយរាក់ទាក់ ពីព្រោះ

ក–ព្រះអង្គចង់ចូលសាសនាគ្រិស្ត ?

ខ–ព្រះអង្គបានត្រូវគេចាប់បង្ខំ ?

គ–ព្រះអង្គខ្សោយ ហើយចង់បានការគាំពារពីពួកគេ ដើម្បីទប់ទល់នឹងសត្រូវរបស់ទ្រង់ ?

ចំលើយ ៖ ទំព័រ៤៤

### សំណាញ់ពីងពាងថា

ជនបរទេស ដែលបានមកមើលប្រាសាទអង្គរ ហើយបានសរសេរស្នាដៃទុកមុនគេ គឺជនជាតិចិនឈ្មោះ ជីវ តាក្វាន់។ គាត់បានមកស្នាក់នៅក្រុងអង្គរនៅឆ្នាំ ១២៩៦–១២៩៧ ហើយបានសរសេរពណ៌នាពីរាជធានី ជីវភាព ទំនៀមទំលាប់ អ្នកស្រុក និងស្ថាប័ននានានៅចុងសម័យអង្គរ។

ក្រោយមក នៅឆ្នាំ១៨៧៣ លោកដឺឡាព័ក (អ្នករុករកជាតិបារាំង) បានគូររូបប្រាសាទអង្គរវត្ត។



# ការវាយលុករបស់សៀម និងការបែកបន្ទាយលង្វែក

ចុងសតវត្សទី១៦

នាសម័យលង្វែក កម្ពុជាសំបូររុងរឿងខ្លាំងក្លាឡើងវិញហើយ។ ប៉ុន្តែនៅចុងសតវត្សទី១៦ ឫទ្ធានុភាពរាជាណាចក្រខ្មែរបានថយចុះ។ សៀមក៏បានលើកទ័ព និងប្រើឧបាយកលផ្សេងៗចូលវាយលុកកម្ពុជា រហូតវាយយកក្រុងលង្វែកបាននៅឆ្នាំ១៥៩៤។



### ចាញ់បោកសង្ឃក្លែងក្លាយ

« សៀមឡោមព័ទ្ធក្រុងលង្វែកអស់៣ខែ តែវាយពុំបែកឡើយ ដោយហេតុថា ក្រុងលង្វែកមានព្រះពុទ្ធរូបមួយព្រះអង្គពូកែណាស់។ ព្រះនរេសូរ បានបញ្ជូនសង្ឃក្លែងក្លាយ២អង្គ ដែលចេះមន្តអាគមមកបន្សាបបារមីព្រះពុទ្ធរូបនោះ។ ថ្នាំរបស់សង្ឃក្លែងក្លាយធ្វើអោយព្រះអង្គខូចព្រះសតិ... ដោយសេចក្តីវង្វេង ព្រះបាទសត្ថាបញ្ជាអោយគេយកព្រះពុទ្ធរូបនោះទៅចោល។ ក្រោយមកព្រះនគរក៏ជួបគ្រោះមហន្តរាយជាច្រើន។ »

(តាមឯកសារមហាបុរសខ្មែរ)

### ▶ ការវាយលុករបស់សៀម

ព្រះបាទសត្ថាទី១ (១៥៧៦–១៥៨៦) ដែលជាបុត្រាច្បងរបស់ព្រះបាទបរមរាជា បានសោយរាជ្យបន្តពីព្រះបិតា។ នៅគ.ស.១៥៨០ ពួកភូមាបានវាយលុកចូលប្រទេសសៀមទៀត ស្តេចសៀមក៏ផ្ញើសារមកថ្វាយព្រះមហាក្សត្រខ្មែរដើម្បីសុំជំនួយ។ ដោយមានព្រះទ័យស្មោះត្រង់នឹងសម្ព័ន្ធភាពខ្មែរ–សៀម ឆ្នាំ១៥៧៤ ព្រះបាទសត្ថាទី១បានអោយសម្តេចស្រីសុរិយោពណ៌ ជាអនុជនិងជាមហាឧបរាជ លើកទ័ពទៅជួយសៀម។ ពេលឈ្នះភូមាហើយ បុត្រាស្តេចសៀមនាម នរេសូរ មិនបានដឹងគុណខ្មែរទេ តែបែរជាប្រមាថមើលងាយមេទ័ពខ្មែរទេវិញ។ តាមពិត នរេសូរបានចិញ្ចឹមចិត្តវាយយកស្រុកខ្មែរដាក់ជាចំណុះជាយូរមកហើយ ដោយរំលោភលើសម្ព័ន្ធភាពឆ្នាំ១៥៧៤។ ដោយហេតុនោះ សៀមបានរៀបចំធ្វើសង្គ្រាមធំមួយយ៉ាងម៉ត់ចត់។ នៅឆ្នាំ១៥៨៨ ក្នុងរាជ្យព្រះជ័យជេដ្ឋាបុត្រាព្រះសត្ថា សៀមចាប់ផ្តើមធ្វើសង្គ្រាមទន្ទ្រានយកទឹកដីខ្មែរ។ ទ័ពសៀមដែលមាន«ទាហានចំនួន ១០០ ០០០នាក់ ដំរី៨០០ និងសេះចំនួន ១ ៨៥០»បានវាយយកខេត្តនគររាជ បាត់ដំបង ពោធិ៍សាត់ រួចហូសមកឡោមព័ទ្ធបន្ទាយបរិបូណ៌។ ទ័ពខ្មែរទន់ដៃ ហើយដកថយ។ ទីបំផុតទ័ពសៀមបានមកឡោមព័ទ្ធទីក្រុងលង្វែកអស់៣ខែ។

### សំណាញ់និងទេថា

រឿងព្រះគោព្រះកែវ ដែលជារឿងសរសេរជាពាក្យកាព្យនិទានពីការបែកក្រុងលង្វែក។

### ▶ ការបែកបាក់បន្ទាយលង្វែក ១៥៩៤

ទីក្រុងលង្វែកការពារដោយព្រះស្រីសុរិយោពណ៌ អនុជព្រះបាទសត្ថាទី១ ហាក់ដូចជាមាំមួនណាស់ មិនអាចវាយយកបានឡើយ។ ព្រៃឫស្សីព័ទ្ធជុំវិញយ៉ាងក្រាស់សំរាប់ធ្វើជារបងការពារមិនអោយសត្រូវចូលបាន។ នៅទីបំផុត ទ័ពខ្មែរបានវាយទ័ពសៀមផ្ទប់គ្នាពីគ្រប់ទិស ធ្វើអោយពួកនេះរត់ខ្ចាត់ខ្ចាយអស់ទៅ។ ប៉ុន្តែមុននឹងដកទ័ពថយទៅស្រុកវិញ សៀមប្រើឧបាយកលយកប្រាក់ដួងច្រកក្នុងកាំភ្លើង ហើយបាញ់ទៅក្នុងគុម្ពឫស្សី។ បន្ទាប់មករាស្ត្រខ្មែរនាំគ្នាកាប់ឆ្ការព្រៃឫស្សី ដើម្បីរើសយកប្រាក់ដួង។ នៅឆ្នាំ១៥៩៣ ពេលសៀមលើកទ័ពចូលមកម្តងទៀត ទ័ពខ្មែរខាងជើងទឹកចាញ់សៀម ឯទ័ពខ្មែរជើងគោកទប់សត្រូវពុំជាប់ ហើយដកថយរហូត។ សៀមវាយសំរុកខ្លាំងឡើងៗ។ នៅទីបំផុតសៀមក៏វាយយកបន្ទាយលង្វែកបាននៅឆ្នាំ១៥៩៤។ សត្រូវដុតបំផ្លាញ និងវាយកំទេចបន្ទាយនេះ។ ទ្រព្យសម្បត្តិ ក្បួនខ្នាត ឯកសារផ្សេងៗ និងមនុស្សត្រូវបានបំផ្លាញ កាប់សំលាប់ រឺនាំយកទៅស្រុកសៀម។ ព្រះស្រីសុរិយោពណ៌ ព្រះរាជវង្សអ្នកប្រាជ្ញបណ្ឌិត និងប្រជារាស្ត្រខ្មែរប្រមាណ ៩០ ០០០នាក់ ត្រូវសៀមចាប់ជាឈ្លើយនាំយកទៅក្រុងអយុធ្យា។ ឯព្រះបាទសត្ថាបានភៀសខ្លួនទៅប្រទេសលាវ។

« សៀមយកប្រាក់ដួងចំនួន ៥ ០០០ដួង ច្របល់នឹងគ្រាប់សំណច្រកក្នុងកាំភ្លើងធំ–តូច បាញ់ទៅក្នុងគុម្ពឫស្សី។ »

(ឯកសារមហាបុរសខ្មែរ)

### សាកល្បងរកចំលើយ

នៅពេលសៀមដកទ័ពត្រលប់ទៅអយុធ្យាវិញ ប្រជារាស្ត្រខ្មែរនាំគ្នាកាប់ឆ្ការព្រៃឫស្សីដើម្បីយកប្រាក់ដួង។ ពួកគេធ្វើដូចនេះដោយ

ក–មានគេបង្ខំ ?

ខ–មានចិត្តលោភចង់បាន ?

គ–មានចិត្តប្រមាទថាសៀមរាងចាលលែងមកទៀតហើយ ?

ចំលើយ : ទំព័រ៤៤

### ក្នុងសភាពច្របូកច្របល់

ព្រះបាទសត្ថាទី១សុគតនៅប្រទេសលាវ។ រាមាជើងព្រៃ (១៥៩៤-១៥៩៦) ដែលជាប់ព្រះញាតិនឹងព្រះអង្គ ងើបឡើងសំលាប់មេទ័ព និងពលសៀមនៅលង្វែក រំដោះនគរបានមកវិញ តែទ្រង់ត្រូវជនជាតិអឺរ៉ុបធ្វើគុត។ ឯព្រះពញាតន់(១៥៩៦-១៥៩៩) ព្រះពញាអន(១៥៩៩-១៦០០) និងព្រះពញាញោម(១៦០០-១៦០៣) ក៏បានត្រូវគេធ្វើគុតដែរ។ នៅឆ្នាំ១៦០៣ ទើបព្រះបាទស្រីសុរិយោពណ៌ ឡើងគ្រងរាជ្យ។

ផ្លាកសញ្ញា «ក្រុមហ៊ុនឥណ្ឌាខាងកើត» របស់ពួកហូឡង់

### សំណាញ់នឹងមេថា

ព្រះបាទស្រីសុរិយោពណ៌ (១៦០៣-១៦១៨) បានមកគង់នៅកោះស្លាកែត ជិតភូមិកៀនស្វាយ រួចនៅរាជវាំងល្វាឯម ត្រង់វត្តអរិយក្សត្រសព្វថ្ងៃ។

# ឥទ្ធិពលបរទេស

## សតវត្សទី១៧

**នៅសតវត្សទី១៧ ជាពិសេសក្រោយពេលដែលព្រះបាទជ័យជេដ្ឋាទី២សោយទិវង្គតទៅ វិបត្តិដណ្តើមរាជ្យសម្បត្តិក្នុងរាជវង្ស បានធ្វើអោយកម្ពុជាច្របូកច្របល់ បែកបាក់គ្នាចុះខ្សោយ រួចធ្លាក់ក្រោមឥទ្ធិពលបរទេស។**

### ▶ ឥទ្ធិពលអឺរ៉ុប

តាំងពីមុនបែកលង្វែកម្ល៉េះ ព្រះបាទបរមរាជាបានចុះព្រះហស្តលេខាលើលិខិតនិងសន្ធិសញ្ញាជាច្រើន ដើម្បីសុំជំនួយយោធាពីពួកអឺរ៉ុប។ ប៉ុន្តែពួកគេគ្រាន់តែមកធ្វើជំនួញ រឺផ្សព្វផ្សាយសាសនាប៉ុននោះ។ លុះយូរៗទៅពួកគេនឹកស្មានថាអាចធ្វើអ្វីក៏បាន ពួកគេក៏បង្កជំលោះនៅគ្រប់ទីកន្លែង។ បន្ទាប់ពីមានជំលោះធំមួយ ដែលធ្វើអោយពួកគេស្លាប់អស់មួយចំនួន ខ្មែរក៏ដេញពួកគេអោយចេញទៅវិញ។ ដូចនេះឥទ្ធិពលរបស់ពួកអេស្ប៉ាញនិងប៉ទុយកាល់ សឹងតែត្រូវបញ្ចប់នៅកម្ពុជាក្នុងឆ្នាំ១៥៩៩។ ប៉ុន្តែក្រោយមក មានជនជាតិអឺរ៉ុបផ្សេងៗ ដូចជាពួកហូឡង់ជាដើម ជាបព្វជិតនិងជាឈ្មួញ បានមកដល់ទៀតជាហូរហែ។ ក្រោយការបែកបន្ទាយលង្វែកភ្លាម គឺក្នុងរាជ្យព្រះបាទរាមាជើងព្រៃ ពួកអ្នកផ្សងព្រេងជាតិប៉ទុយកាល់និងជនជាតិអេស្ប៉ាញបានត្រលប់មកកម្ពុជាវិញ។ ពួកគេបានទាំងចូលរួមក្នុងព្រឹត្តិការណ៍ខ្លះៗទៀតផង។ រាជាណាចក្រខ្មែរ ដែលបែកបាក់ដោយចំបាំងច្រើនលើកជាមួយសៀមនោះ ត្រូវការទ័ពខ្លាំងពូកែរបស់ពួកអឺរ៉ុបព្រមទាំងបច្ចេកទេសនិងទាហានរបស់ពួកគេថែមទៀត។

### ▶ ឥទ្ធិពលសៀម និងយួន

នៅឆ្នាំ១៦០១ ព្រះស្រីសុរិយោពណ៌ ដែលជាប់ឃុំឃាំងនៅស្រុកសៀមតាំងពីបែកបន្ទាយលង្វែកមកនោះ បានយាងត្រលប់មកវិញ ហើយព្រះអង្គបានឡើងគ្រងរាជ្យ។ ដោយទ្រង់បានគង់នៅប្រទេសសៀមយូរ ទើបទ្រង់បាននាំយកទំនៀមទំលាប់ ច្បាប់និងពិធីការក្នុងព្រះបរមរាជវាំងសៀមមកតាម ៖ ជាឧទាហរណ៍ ស្តេច និងអ្នកមានបណ្តាសក្តិទ្រង់ព្រះភូសា គឺអាវផាយបែបថៃពណ៌លឿង។ ក្នុងរយៈកាលដំបូង សៀមច្រើនតែបង្ខំខ្មែរអោយទទួលស្គាល់អំណាចគេ ហើយនាំសួយសារអាករទៅជូនគេ។ នៅឆ្នាំ១៦១៨ ព្រះបាទស្រីសុរិយោពណ៌បានដាក់រាជ្យថ្វាយបុត្រាច្បងនាមជ័យជេដ្ឋាទី២។ ក្នុងព្រះរាជបំណងយកកំលាំងយួនមកទប់ទល់នឹងកំលាំងសៀម ព្រះបាទជ័យជេដ្ឋាទី២បានរៀបអភិសេកជាមួយអង្គចូវជាបុត្រីស្តេចយួនអោយឡើងជាមហេសី។ ក្សត្រីអង្គចូវបានផ្តល់កន្លែងសំខាន់ៗទៅអោយអ្នកសំណាញ។ ពួកយួនមកតាំងនៅកម្ពុជា បើកគ្រឹះស្ថានជំនួញ និងសាខាគ្រឹះស្ថានជំនួញជាច្រើននៅឧដុង្គ និងជាពិសេសនៅព្រៃនគរ ដែលកាលនោះជាក្រុងមួយរបស់ខ្មែរ។ ដោយបារម្ភខ្លាចកម្ពុជារបូតចេញពីឥទ្ធិពលរបស់ខ្លួន សៀមបានលើកទ័ពមកវាយខ្មែរពីរលើក (នៅឆ្នាំ១៦២១ និងឆ្នាំ១៦២២) តែត្រូវបរាជ័យរាល់លើក។ ក្នុងរយៈពេលជាង២សតវត្ស ព្រះរាជាណាចក្រខ្មែរចូលទៅក្នុងចន្លោះឥទ្ធិពលសៀមនិងយួន។

ព្រះរាជាខ្មែរទទួលពួកឈ្មួញយួន។



### ដំណើរចុះទៅទិសខាងត្បូង

នៅស.វ.ទី១៥ យួនបានឯករាជ្យឡើងវិញផុតពីការគ្រប់គ្រងរបស់ចិន។ យួនបានបន្តធ្វើដំណើរចុះតាមឆ្នេរសមុទ្រឆ្ពោះទៅខាងត្បូងដើម្បីស្វែងរកទឹកដីសំបូរជីជាតិ។ ចាប់ពីឆ្នាំ១៤៧១មកយួនចាប់ផ្តើមយកនគរចាម្ប៉ាបន្តិចម្តងៗ រហូតបានទាំងស្រុងនៅស.វ.ទី១៧។ នគរយួនក៏មានព្រំដែនជាប់នឹងនគរខ្មែរ។ ក្នុងការបន្តចុះទៅត្បូងទៀត ពួកយួនបានចូលកាន់កាប់បន្តិចម្តងៗអាណាខេត្តទាំងអស់នៃដែនដីខ្មែរដែលមានឈ្មោះថាកម្ពុជាក្រោម។

# ជ័យជេដ្ឋាទី២-ស្ថាបនិកក្រុងឧដុង្គ

១៦១៨-១៦២៨

ក្រោយបែកក្រុងលង្វែក កម្ពុជាធ្លាក់ក្នុងសភាពច្របូកច្របល់។ មានស្តេចច្រើនអង្គឡើងសោយរាជ្យក្នុងរយៈពេលខ្លីៗ។ នៅឆ្នាំ១៦២០ ជ័យជេដ្ឋាទី២ យាងមកតាំងរាជធានីនៅឧដុង្គ។ ពីឆ្នាំនោះ ដល់ឆ្នាំ១៨៦៧ ស្តេចខ្មែរសឹងតែគ្រប់អង្គតែងគង់នៅឧដុង្គ។ ដំណែលពីសម័យនោះ មានសេសសល់នៅភ្នំឧដុង្គ។

### សំណាញ់ដឹងមេថា

ព្រះរាជវាំងសម័យឧដុង្គស្ថិតនៅខាងជើងភ្នំឧដុង្គ។ សំណង់ទាំងឡាយសុទ្ធតែធ្វើអំពីសំភារៈឆាប់ពុកផុយ។ ដូចនេះ ដោយសង្គ្រាម អាកាសធាតុ និងពេលវេលា ពុំមានអ្វីនៅសេសសល់ឡើយ។

### សាកល្បងរកចំលើយ

ភ្នំឧដុង្គ មានឈ្មោះថា «ភ្នំព្រះរាជទ្រព្យ» ផងដែរ ពីព្រោះភ្នំនេះ

ក-នៅក្បែររាជធានីឧដុង្គ ដែលព្រះរាជាគង់នៅ ?

ខ-ជាកន្លែងដែលព្រះរាជាតែងទៅក្រសាល ?

គ-ជាកន្លែងស្ថាបនាឡើង និងថែរក្សាដោយទ្រព្យសម្បត្តិផ្ទាល់របស់ព្រះរាជា ?

ចំលើយ : ទំព័រ៤៤






### ខ្លះៗពីភ្នំឧដុង្គ ឬ ភ្នំព្រះរាជទ្រព្យ ឬ ភ្នំអដ្ឋរស្ស

- ជាកូនភ្នំ សណ្ឋានយ៉ាងវែងទទឹងថ្ងៃ នៅក្នុងស្រុកពញាឮ ខេត្តកណ្តាល។
- មានបណ្តោយប្រហែល១ ៥០០ម និងកំពូលខ្ពស់បំផុតប្រមាណ២០០ម។
- មានចំងាយ ៤០គម ពីភ្នំពេញ : ៣៧គម តាមផ្លូវជាតិលេខ៥ + ៣គម តាមផ្លូវចូល។
- ជាអតីតបូជនីយដ្ឋានសំរាប់បញ្ចុះព្រះអដ្ឋិធាតុព្រះរាជវង្ស។
- សព្វថ្ងៃ មានព្រះសក្យមុនីចេតិយ ជាកន្លែងដែលព្រះបរមសារីរិកធាតុគង់នៅតាំងពីខែធ្នូ ឆ្នាំ២០០២។






# រាជសំភារ ចៅពញាតូ-កវីល្បីឈ្មោះ

១៦២៩-១៦៣៤

**ពីពញា...**
**មៅព្រះអង្គម្ចាស់**

កាលពីបុរាណ គេប្រើពាក្យ ពញា សំរាប់ហៅព្រះរាជបុត្រ ក្សត្រគ្រងរាជ្យ ឧទាហរណ៍ ពញាយ៉ាត ពញាតូ ពញាចន្ទ ជាដើម។ បន្ទាប់មក ពាក្យ ពញា បានត្រូវប្តូរទៅជា អង្គ វិញ ដូចជា អង្គអេង អង្គតន់ អង្គឌួងជាដើម។ ក្រោយមកទៀត ពាក្យអង្គ ក៏ប្តូរទៅជា ព្រះអង្គម្ចាស់វិញ រហូតមកដល់សព្វថ្ងៃ។

១ គូស្នេហ៍ត្រូវគេដេញតាម។
២ ព្រះរាជសំភារទៅពួនលើចុងត្នោត។ ទ្រង់ចារកំណាព្យលើស្លឹកត្នោតទុកជាជំបូន្មាន។





**កាលព្រះបាទជ័យជេដ្ឋាទី២សុគតនៅឆ្នាំ១៦២៨ អនុជព្រះអង្គ នាមព្រះឧទ័យបានកាន់កាប់អំណាចបណ្តោះ-អាសន្ន។ នៅឆ្នាំ១៦២៩ ទើបបុត្រាព្រះអង្គនាមរាជសំភារ ចៅពញាតូ ឡើងគ្រងរាជ្យ នៅកោះឃ្លោក(ខ្សាច់កណ្តាល)។**

ព្រះរាជសំភារ ចៅពញាតូ (ស្រីធម្មរាជាទី២) គ្មានចំណូលចិត្តចង់សោយរាជ្យទេ។ ព្រះអង្គមានមេត្តាធម៌ ឆាប់រំភើប ស្រលាញ់អក្សរសាស្ត្រ និងសិល្បៈ។ ព្រះអង្គចាកចោលគូដណ្តឹងនាមចន្ទវតី (ខ្លះថាបុប្ផាវតី) ដើម្បីទៅបួសនៅឯអង្គរវត្ត។ ក្សត្រីអង្គនេះក៏បានរៀបអភិសេកជាមួយព្រះឧទ័យ ដែលត្រូវជាឪពុកមាព្រះអង្គ និងជាឧបរាជ។ បន្ទាប់មក ចៅពញាតូបានចាកសិក្ខាបទ ហើយឡើងសោយរាជ្យ។ ព្រះអង្គនិងចន្ទវតីចាប់ស្រលាញ់គ្នាឡើងវិញ។ គូសង្សារទាំងពីរសរសេរលិខិតផ្អែមល្ហែមឆ្លើយឆ្លងគ្នា និងតែងរកឱកាសជួបគ្នា។ ថ្ងៃមួយ ចន្ទវតីបានយាងចូលរាជវាំង ដើម្បីជួបព្រះរាជា។ ព្រះឧទ័យខ្ញាល់ខ្លាំង ក៏លើកទ័ពចេញទៅតាម មានទាំងជនបរទេសផង។ ព្រះរាជសំភារច្បាំងចាញ់ ហើយភៀសខ្លួនជាមួយចន្ទវតី។ គូស្នេហ៍ទាំងពីរត្រូវគេតាមទាន់។ ព្រះអង្គឡើងទៅពួនលើចុងត្នោត រួចត្រូវគេធ្វើគុតដោយប្រើកាំភ្លើងបាញ់ទំលាក់ ឯព្រះក្សត្រីត្រូវគេចាប់យកទៅធ្វើទោស។ ចៅពញានូរីអង្គទងរាជា អនុជព្រះរាជសំភារឡើងគ្រងរាជ្យ (១៦៣៥) រហូតទ្រង់ចូលទិវង្គតនៅគ.ស.១៦៣៩។ បន្ទាប់មក ព្រះឧទ័យក៏បង្កអោយមានការជ្រែករាជ្យ ដោយបង្វែររាជ្យទៅថ្វាយបុត្រាខ្លួននាម បទុមរាជាអង្គនន់វិញ (១៦៣៩-១៦៤១)។

សាធុសម្តាយ
តែងអោយវែងឆ
កុំថិរាយមាយ
ក្នុងវង្គសង្សារ
បានសោយតែទុក្ខ។
និងក្តីកាមា
ស្ទាប់ទៅកាលណា



# ពញាចន្ទ-ព្រះរាជាកាន់សាសនាអ៊ិស្លាម

១៦៤១-១៦៥៩

**ពញាចន្ទ អនុជពៅរបស់ចៅពញាតូ ជាអ្នកស្នងរាជ្យស្រប ច្បាប់។ ព្រះអង្គម្ចាស់នេះបានអោយគេសំលាប់ព្រះឧទ័យ ព្រះមហាក្សត្របទុមរាជាអង្គនន់ និងបុត្រា។ ពញាចន្ទឡើង សោយរាជ្យ (គ.ស. ១៦៤១) នៅក្រុងឧដុង្គ ដោយមាននាម ថា ព្រះបាទរាមាធិបតីទី១។**

ពញាចន្ទមានព្រះនាមល្បីថាកាចសាហាវ និងឆាប់ក្រេវក្រោធ។ ទ្រង់ស្រលាញ់ក្រមុំចាម (ជ្វា?) ស្រស់ស្អាតម្នាក់ ហើយលើកនាងជាស្នំឯក។ ដោយហេតុនោះ ព្រះអង្គក៏ទ្រង់ប្តូរទៅកាន់សាសនាអ៊ិស្លាមវិញ រួចយកព្រះនាមថា អ៊ីប្រាហ៊ឹម។ ឯប្រជារាស្ត្រខ្មែរ ដែលជាពុទ្ធសាសនិកនោះ ក៏មានការអាក់អន់ចិត្តជាខ្លាំង ហើយហៅព្រះអង្គថា «ព្រះរាមចូលសាសន៍»។ បន្ទាប់មក ភាពវឹកវរនិងសង្គ្រាមស៊ីវិលក៏បានឆាបឆេះឡើង។ បុត្រាព្រះឧទ័យពីរអង្គ នាមអង្គសូរ និងអង្គតន់ ដែលបានគេចផុតពីការសំលាប់រង្គាលពីមុននោះ បានងើបឡើងសងសឹក ដោយទៅពឹងពាក់ក្សត្រីអង្គចូវ និងសុំជំនួយពីយួន។ ព្រះរាមចូលសាសន៍ច្បាំងចាញ់ ហើយត្រូវគេចាប់ដាក់ទ្រុងដែកបញ្ជូនទៅស្រុកយួន។ អង្គសូរឡើងសោយរាជ្យ (១៦៥៩-១៦៧២) ប៉ុន្តែត្រូវលើកសួយសារអាករទៅថ្វាយស្តេចយួន។ ចាប់ពីពេលនោះមក យួនតែងតែលូកដៃចូលកិច្ចការផ្ទៃក្នុងរបស់ខ្មែរមិនឈប់ឈរ។ ក្នុងភាពច្របូកច្របល់នេះ ពួកអឺរ៉ុបបានវិលត្រលប់មកវិញ។ ក្នុងចំណោមពួកនោះ ពួកហូឡង់ស្អប់ពួកប័ទុយកាល់ ហើយចង់បានសិទ្ធិធ្វើជំនួញផ្តាច់មុខ។ ដំបូងឡើយព្រះរាមចូលសាសន៍អនុគ្រោះជនជាតិហូឡង់ តែក្រោយមកបែរជាអោយគេសំលាប់ពួកនេះទៅវិញ។

**ព្រះរាមចូលសាសន៍**

បន្តិចក្រោយមក ព្រះរាជាបានចូលសាសនាអ៊ិស្លាមវិញ អោយគេកាត់ចុងអង្គជាតិរបស់ព្រះអង្គ និងប្រកាសថា ជាអ្នកកាន់សាសនាអ៊ិស្លាម ហើយធ្វើអ្វីៗសព្វបែបយ៉ាង ដើម្បីទាក់ទាញពួកចាមជ្វា។



ទ័ពយួនចូលមកស្រុកខ្មែរ ជាដំបូង។

# វិបត្តិដណ្ដើមរាជសម្បត្តិ

## សតវត្សទី១៧

ក្នុងរយៈពេលជាងមួយសតវត្ស ព្រះញាតិវង្សឈ្មោះដណ្ដើមរាជសម្បត្តិគ្នាមិនឈប់ឈរឡើយ។ ដើម្បីឈ្នះនិងសំលាប់គូប្រជែងព្រះអង្គម្ចាស់មួយអង្គទៅពឹងយួន ឯមួយអង្គទៀតទៅពឹងសៀម។ ក្នុងចំបាំងសំលាប់បងប្អូនឯងកាលនោះ ព្រះរាជវង្សលែងគិតគូរដល់បេសកម្មរបស់ខ្លួនហើយ។

### ▶ ស្ដេចមិនស្ថិតស្ថេរ

ក្រោយពីមានការបះបោររបស់ពួកចាមជាអ្នកគាំទ្រពញាចន្ទបន្តិចមក ព្រះបរមរាជាអង្គសូរ (១៦៥៩-១៦៧២) បានត្រូវបុត្រប្រសារបស់ព្រះអង្គនាមស្រីជ័យជេដ្ឋធ្វើគុត (១៦៧២)។ ប៉ុន្តែស្ដេចអង្គនេះក៏ត្រូវមហេសីខ្លួនធ្វើឃាតបន្តទៀត (១៦៧៣)។ បុត្រារបស់ព្រះបរមរាជាអង្គសូរ នាមកែវហ្វាអង្គជី ឡើងសោយរាជ្យ (១៦៧៣-១៦៧៥) ហើយត្រូវប្រយុទ្ធនឹងទ័ពខ្មែរ-យួន ដែលមានយួន១០ ០០០នាក់ជាជំនួយដល់អង្គនន់ ជាជីដូនមួយរបស់ទ្រង់។ ក្នុងចំបាំងចុងក្រោយ អង្គជីទ្រង់ប្រឈួន ហើយសុគតទៅនៅឆ្នាំ១៦៧៥។ ព្រះអនុជនាមអង្គសូ (ចៅពញាសូ) ឡើងស្នងរាជ្យបន្ត រួចធ្វើអោយទ័ពខ្មែរ-យួនបរាជ័យ ហើយអង្គនន់ត្រូវភៀសខ្លួនទៅស្រុកយួនម្ដងទៀត។ ព្រះអង្គសូ ជាអនាគតព្រះស្រីជ័យជេដ្ឋា វីជ័យជេដ្ឋាទី៣។ ព្រះរាជាអង្គនេះដាក់រាជ្យ៥លើក : លើកទី១ដើម្បីថ្វាយទៅព្រះមាតាបីខែ (គ.ស.១៦៨៨) ពេលទ្រង់មានជំងឺ លើកទី២ដើម្បីថ្វាយទៅក្មួយនាមព្រះឧទ័យរាជា (១៦៩៥) ដែលទ្រង់សុគតក្រោយនោះបន្តិច លើកទី៣ដើម្បីថ្វាយទៅបុត្រប្រសានាមអង្គអិម (១៦៩៩-១៧០០) ដែលគ្មានសមត្ថភាព លើកទី៤ដើម្បីថ្វាយទៅព្រះរាជបុត្រនាមធម្មរាជា (១៧០២-១៧០៣) ដែលនៅក្មេងពេកពុំអាចទប់ទល់នឹងយួនបាន ហើយលើកទី៥ដើម្បីថ្វាយទៅព្រះរាជបុត្រដដែលនោះទៀត (១៧០៦-១៧០៩) រួចទើបព្រះអង្គយាងទៅសាងផ្នួស។

**តំរូមិនល្អមួយ!**
ព្រះស្រីជ័យជេដ្ឋា វីជ័យជេដ្ឋាទី៣ បានដាក់រាជ្យ ហើយឡើងសោយរាជ្យវិញ៥ដង។ ឧទាហរណ៍មិនល្អនេះ បានបង្កើតជាគំរូអាក្រក់ដល់ស្ដេច ដែលសោយរាជ្យបន្តក្រោយៗមកទៀត រហូតដល់ពាក់កណ្ដាល ស.វ.ទី១៨។ អស្ថិរភាពនេះ និងការវាយប្រហាររបស់ពួកឈ្លានពានយួន និងសៀមបានទាញកម្ពុជាអោយធ្លាក់ចុះយ៉ាងលឿន និងលែងមានមុខមាត់។

**សាកល្បងរកចំលើយ**

ជំលោះដណ្ដើមរាជបល្ល័ង្កក្នុងរាជវង្សខ្មែរ ដែលអូសបន្លាយយ៉ាងយូរអង្វែងបណ្ដាលមកពី
ក-ការមិនគោរពច្បាប់ស្នងរាជ្យ ?
ខ-ការលោភលន់របស់ពួកអង្គម្ចាស់ ?
គ-ការជ្រៀតជ្រែកពីពួកអឺរ៉ុប ?

ចំលើយ : ទំព័រ៤៤

នៅសម័យនោះ ស្ដេចបារាំងព្រះនាម ល្វី ទី១៤ សាងសង់ប្រាសាទ វែរសៃ។ ឯនៅអាស៊ី ពួកម៉ាន់ជូវាយយកបានប្រទេសចិនពីរាជវង្ស មិញ និងធ្វើអោយជនជាតិចិនជាច្រើនភៀសខ្លួនមកនៅប្រទេសខ្មែរ។



### ▶ ចន្លោះសៀម និងយួន

ព្រះអង្គម្ចាស់ ដែលត្រូវគេកំចាត់ចេញពីរាជបល្ល័ង្ក មានការអាក់អន់ចិត្ត។ ព្រះអង្គរត់ទៅជ្រកកោននៅស្រុកសៀម វឺនៅស្រុកយួន។ ព្រះអង្គលើកទ័ពពីនគរនោះត្រលប់មកច្បាំងដណ្ដើមយករាជបល្ល័ង្កវិញ។ ដោយហេតុនេះ នគរខ្មែរក្លាយទៅជាទីលានសំរាប់ប្រទេសជិតខាងលើកទ័ពចូលមកធ្វើអន្តរាគមន៍។ អង្គអិម ដែលត្រូវព្រះបិតាក្មេក គឺព្រះជ័យជេដ្ឋាទី៣ (អង្គសូ) យករាជសម្បត្តិមកវិញព្រោះតែអសមត្ថភាពនោះ ទំនងជាមានគំនុំ ក៏រត់ទៅកម្ពុជាក្រោម កែនទ័ព ហើយមកវាយក្រុងឧដុង្គវិញ ដើម្បីដណ្ដើមរាជ្យពីធម្មរាជា ដែលជាអនុជថ្លៃ។ អង្គអិមឡើងសោយរាជ្យជាលើកទី២ ដោយយកព្រះនាមថាព្រះកែវហ្វាទី៣អង្គអិម។ ឯធម្មរាជា ក៏ភៀសព្រះអង្គទៅសុំជំនួយពីសៀម ហើយវិលត្រលប់មកច្បាំងដណ្ដើមយករាជសម្បត្តិវិញ។ ប៉ុន្តែពេលជួយច្បាំងឈ្នះហើយ សៀមនៅបន្តទុកព្រះអង្គអិមអោយសោយរាជ្យនៅឧដុង្គដដែល ព្រោះព្រះអង្គអិមព្រមនាំស្លួយសារអាករទៅចំណុះប្រទេសសៀមវិញ។ ពេលនោះ សៀមក៏នាំយកធម្មរាជាអភ័ព្វទៅអយុធ្យាវិញទៅ។

**ប្រជារាស្ត្រខ្មែរ**
ក្នុងភាពវឹកវរ ហើយជូនកាលក្នុងសង្គ្រាម រាស្ត្រខ្មែរនៅតែបំពេញការងារសំរាប់ជីវិតប្រចាំថ្ងៃ។ ពិតមែនហើយ ព្រៃព្រឹក្សាបានគ្របដណ្ដប់លើភាពរុងរឿងសម័យអង្គរ ដែលគេសឹងតែភ្លេចទៅហើយ។ ប៉ុន្តែកម្ពុជាដែលធ្លាក់ចុះក្រនិងបែកបាក់គ្នានៅរក្សាបានកំលាំងនិងអត្តសញ្ញាណរបស់ខ្លួន។ ខ្មែរគោរពបូជាព្រះពុទ្ធ ក្នុងពេលសប្បាយ ក៏ដូចជាក្នុងពេលទុក្ខព្រួយដែរ។ ជីវភាពប្រចាំថ្ងៃរបស់ពួកគេផ្សារភ្ជាប់ទៅនឹងវត្តអារាមដូចសព្វថ្ងៃនេះដែរ។



ជីវភាពប្រចាំថ្ងៃរបស់ប្រជាជននៅបន្ត ទោះជាក្នុងពេលមានសឹកសង្គ្រាមក៏ដោយ។

# ទឹកដីខ្មែរក្នុងចំបាំង និងល្បិចកល

## សតវត្សទី១៨

ជំលោះក្នុងរាជវង្សដើម្បីដណ្តើមរាជបល្ល័ង្ក នៅតែបន្ត។ នៅដើមសតវត្សទី១៨ យួនបាន រំលោភចូលកាន់កាប់ខេត្តរបស់ខ្មែរនៅកម្ពុជា ក្រោមថែមទៀត។ ឯសៀមវិញ នៅពេញ សតវត្សនេះ ក៏បានគាបសង្កត់ខ្លាំងឡើងៗ ដែរមកលើប្រទេសនិងប្រជារាស្ត្រខ្មែរ។



អង្គអេង
ព្រះរាជាវ័យក្មេង

### ការគោរពព្រះរាជា

ក្នុងភាពវឹកវរ សោកសៅខ្លោចផ្សា ងងឹតនៃវិបត្តិផ្ទៃក្នុងនេះ និងចំពោះមុខទិដ្ឋភាពអកុសលបង្កើតឡើងដោយពួកព្រះអង្គម្ចាស់ ប្រជារាស្ត្រខ្មែរនៅតែរក្សាជំនឿនិងទំនុកចិត្តទៅលើព្រះមហាក្សត្ររបស់ខ្លួន។ ព្រះរាជា ទោះជាមានអ្វីកើតឡើងក៏ដោយ ក៏នៅតែជាបុគ្គលពិសិដ្ឋ ជាទីសក្ការៈ ជាស្តេចចក្រវាល ដែលពួកគេតែងគោរពជារៀងរហូតមក។

### ▶ យួនពីទិសខាងកើត

ក្នុងរាជ្យព្រះសត្ថាទី២ អង្គជី ដែលបានស្នងរាជ្យបន្តពីបិតានាមព្រះបាទអង្គអិម ពួកលាវជាឈ្លើយសឹក ដែលនៅខេត្តស្វាយរៀងនាំគ្នាបះបោរ (១៧៣០)។ នេះគឺជាឱកាសមួយដែលយួនចូលធ្វើអន្តរាគមន៍ ហើយយកខេត្តមេសរ និងលង់ហោរ (១៧៣២)។ ដូចនេះ យួនបានចុះមកខាងត្បូងដល់ទន្លេមេគង្គហើយ។ ឯសៀមក៏ចូលលុកលុយកម្ពុជាដែរ ហើយលើកធម្មរាជាអោយសោយរាជ្យឡើងវិញ (រជ្ជកាលទី៣ : ១៧៣៨-១៧៤៧)។ ក្រោយពីធម្មរាជាសុគតទៅ ប្រទេសជាតិមានភាពវឹកវរ។ បន្ទាប់មក ព្រះអង្គទងបានឡើងសោយរាជ្យ (រជ្ជកាលទី១ : ១៧៤៧-១៧៤៨)។ តែព្រះសត្ថាទី២ ហៅយួនអោយជួយ។ ទ័ពខ្មែរទន់ដៃ យួនដេញតាមដល់ឧដុង្គ។ ហ្លួងអង្គទង ក៏ភៀសខ្លួនទៅសៀម។ ព្រះសត្ថាទី២ បានឡើងសោយរាជ្យ។ បន្ទាប់មកព្រះអង្គទងត្រលប់មកវិញ ហើយឡើងសោយរាជ្យបន្ត (រជ្ជកាលទី២ : ១៧៥៦-១៧៥៧)។ ប៉ុន្តែហ្លួងអង្គនេះបានត្រូវព្រះឧទ័យរាជាបណ្តេញចេញដោយសារជំនួយពីយួន។ យួនក៏បានយកខេត្តព្រះត្រពាំង និងខេត្តឃ្លាំង (ផែនទីទំព័រ៤២)។ ព្រះឧទ័យរាជាឡើងសោយរាជ្យ (១៧៥៨-១៧៧៥) ហើយអោយគេចាប់ចៅពីរអង្គរបស់ធម្មរាជាដាក់ក្នុងទ្រុងដែកបញ្ជូនមកក្រុងឧដុង្គ : មួយអង្គត្រូវគេនាំទៅធ្វើគុតនៅឧដុង្គ មួយអង្គទៀត (អង្គនន់) រត់រួចទៅប្រទេសសៀម ដោយសារការរួមគំនិតរបស់នាម៉ឺនម្នាក់។

### ▶ សៀមពីទិសខាងលិច

នៅឆ្នាំ១៧៦៧ ទ័ពភូមាចូលឈ្លានពានក្រុងអយុធ្យាម្តងទៀត ធ្វើអោយរាជបុត្រស្តេចសៀមរត់មកសុំជ្រកកោននៅឧដុង្គ។ ចៅវ៉ាយខេត្តកូនកាត់ចិន-សៀមម្នាក់ឈ្មោះ ពញាតាក បានប្រមូលបក្សពួកវាយកំចាត់ទ័ពភូមា ហើយតាំងខ្លួនជាស្តេច (ព្រះចៅតាកស៊ីន)។ ព្រះឧទ័យមិនទទួលស្គាល់ពញាតាកជាស្តេចសៀមថ្មីទេ។ ពញាតាកខឹង ក៏គាំទ្រអង្គនន់ប្រឆាំងនឹងព្រះឧទ័យវិញ។ សៀមបញ្ជូនទ័ពមកវាយលុកកម្ពុជា ប៉ុន្តែត្រូវចាញ់ទ័ពខ្មែរ។ ពេលនោះ ព្រះរាជនគរមានភាពវឹកវរខ្លាំង។ ដើម្បីបញ្ចប់ការបង្ហូរឈាមគ្នាឯង ព្រះឧទ័យក៏ដាក់រាជ្យថ្វាយទៅគូប្រជែង គឺព្រះអង្គនន់ (១៧៧៥-១៧៧៩)។ ស្តេចអង្គនេះបានរៀបចំការពារទប់ទល់នឹងយួនភ្លាម : គេសិតកាំភ្លើង កិនរំសេវ និងធ្វើបន្ទាយនៅភ្នំពេញ និងនៅមុខកំពូល។ ទ័ពយួនមួយកងបានត្រូវរុញច្រានទៅវិញ។ ប៉ុន្តែព្រះអង្គនន់កែនទ័ពនិងស្បៀងទៅជួយសៀមច្បាំងនឹងលាវ។ កំណែននេះធ្វើអោយមានការបះបោរនៅខេត្តកំពង់ស្វាយ។ មន្ត្រីធំៗបីនាក់ឈ្មោះ មូ ស្ទនិងបែន បានក្បត់ រួចចាប់ស្តេចធ្វើគុត (១៧៧៩)។ មូឡើងកាន់អំណាច ហើយអោយបុត្ររបស់ព្រះឧទ័យនាមអង្គអេង ព្រះជន្ម៧វស្សា ឡើងគ្រងរាជ្យ។ ក្រោយមក ពេលទ័ពសៀមនិងយួនកំពុងច្បាំងគ្នានៅលើទឹកដីខ្មែរ ស្តេចសៀមកើតវិកលចរិត។ ទ័ពសៀមក៏ដកថយទៅវិញ។ មូ ត្រូវបែន និងស្ទសំលាប់ (១៧៨២)។ ស្ទក៏ត្រូវគេសំលាប់តមកទៀត។ ឯបែនក៏ភៀសខ្លួនទៅស្រុកសៀមនាំយកព្រះអង្គអេងនិងរាជវង្សទៅជាមួយផង។

### ជនជាតិយួន

យួនកាន់ពុទ្ធសាសនាមហាយាន និងមានលក្ខណៈខុសប្លែកពីជនជាតិខ្មែរ : យួនទទួលឥទ្ធិពលពីពិភពចិនជាយូរលង់មកហើយ។ សិល្បៈនិងទំនៀមទំលាប់ក៏ផ្សេងពីខ្មែរដែរ។

### ជនជាតិសៀម

សៀមបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីខ្មែរក្នុងវិស័យសិល្បៈ អក្សរសាស្ត្រ និងទំនៀមទំលាប់។ អក្សរសិល្ប៍ វិចិត្រកម្ម ចំលាក់ ស្ថាបត្យកម្មមានលក្ខណៈដូចខ្មែរច្រើន។ ប្រទេសទាំង២ កាន់ពុទ្ធសាសនាហីនយានដូចគ្នា។

### ពីស្តេចខ្មែរទៅស្តេចជ្រែករាជ្យសៀម ពញាតាក

« ព្រះរាជាខ្មែរមិនអាចបន្ទាបខ្លួនអោយស្មើនឹងមនុស្ស ដែលគ្រាន់តែជាកូនកាត់របស់ឈ្មួញចិនជាមួយនឹងស្ត្រីសៀមម្នាក់សាមញ្ញប៉ុននោះ ទោះបីជាអ្នកនោះមានតំលៃប៉ុនណាក៏ដោយ... »

(អង់ដ្រេ មីក)

# អង្គអេង ១៧៧៩-១៧៩៦ និង អង្គចន្ទទី២ ១៨០៦-១៨៣៤
# ស្ដេចទទួលរាជាភិសេកនៅបាងកក

### សំណាញ់នឹងទេថា

នៅពេលព្រះអង្គអេង សោយទិវង្គត បុត្រាព្រះអង្គនៅក្មេងៗពេក។ មន្ត្រីខ្មែរ គឺចៅហ៊្វាប៉ុក ដែលស្និទ្ធនឹងសៀមបានទទួលមើលខុសត្រូវកិច្ចការរដ្ឋពីឆ្នាំ១៧៩៦ ដល់ ១៨០៥។

### នៅក្រោមឥទ្ធិពល សៀមផង យួនផង

ក្នុងរជ្ជកាលព្រះអង្គចន្ទទី២ :

- ខ្មែរត្រូវលើកសួយសារអាករទៅថ្វាយស្ដេចសៀមផង និងស្ដេចយួនផង។
- សួយបញ្ជូនទៅយួនមាន ដំរីឈ្មោលកំពស់៥ហត្ថពីរក្បាល កុយរមាសពីរ ភ្លុកដំរីបីគូ ក្រវាញ ក្រមួន ម្រ័ក្សណ៍...
- យួនកែនខ្មែរអោយជីកព្រែកវិញតេ ប្រវែង៥៣គម និង ព្រែកវិញអាន ប្រវែង១៤គម នៅកម្ពុជាក្រោម។

ក្បួននាំសួយសារអាករ ទៅថ្វាយស្ដេចយួន។

ក្នុងឆ្នាំ១៧៩៤នៅក្រុងបាងកកឯនោះ សៀមបានអភិសេកព្រះបាទអង្គអេងអោយឡើងជាស្ដេចថ្មីរបស់ខ្មែរ។ ដូចគ្នានេះ ស្ដេចស្នងរាជ្យបន្ត គឺព្រះបុត្រានាម អង្គចន្ទទី២ ក៏ទទួលរាជាភិសេកនៅឯស្រុកសៀមដែរ នៅឆ្នាំ១៨០៦។

សៀមនៅតែបន្តក្ដាប់អំណាចមហារាជមកលើខ្មែរ។ បែនជាស្ដេចត្រាញ់ខ្មែរឈរត្រួតខេត្តបាត់ដំបងនិងសៀមរាប មានទាំងកងទ័ព តែត្រូវឡើងផ្ទាល់ទៅព្រះចៅសៀម។ ខេត្តទាំងពីរនេះចំណុះសៀមហើយ។ ឯយួនក៏បានទាមទារសួយសារអាករជាទៀងទាត់ផងដែរ។ ព្រះបាទអង្គចន្ទទី២ត្រូវបង្ខំព្រះទ័យយល់ព្រម។ សៀមមិនសប្បាយចិត្ត ក៏បញ្ជូនទ័ពចូលវាយលុកនគរខ្មែរ។ ព្រះអង្គចន្ទឃើញស្ថានភាពធ្ងន់ធ្ងរ ក៏ភៀសព្រះអង្គទៅកម្ពុជាក្រោម។ នៅឆ្នាំ១៨១៣ ដោយមានទ័ពស្ដេចយួននាម យ៉ាឡុងជង្ហែមកផង ព្រះអង្គចន្ទទី២បានវិលត្រលប់មកសោយរាជ្យនៅឧដុង្គវិញ។ សៀមនិងយួនឆ្លៀតឱកាសយកចំណេញទាំងអស់គ្នា។ សៀមចូលកាន់កាប់ខេត្តមង្គលបុរី ទន្លេរពៅ និងស្ទឹងត្រែង។ ឯយួនបញ្ជាក់ជាផ្លូវការថាទេសាភិបាលយួនឈរនៅកម្ពុជាក្រោមមានអំណាចសំរេចកិច្ចការគ្រប់បែបយ៉ាងលើប្រទេសខ្មែរ។





# ក្សត្រីអង្គម៉ី-អធិជ័យរបស់យួន
## ១៨៣៤-១៨៤០

នៅឆ្នាំ១៨៣៤ ព្រះអង្គចន្ទទី២ចូលទិវង្គត។ យួនដែលចាត់ទុកខ្លួនឯងជាមហារាជនៃស្ដេចខ្មែរ បានកំចាត់អង្គម្ចាស់ណាដែលមានទំនាក់ទំនងនឹងសៀម ហើយលើកបុត្រីព្រះបាទអង្គចន្ទទី២ នាមអង្គម៉ី ព្រះជន្ម២០វស្សាអោយឡើងសោយរាជ្យ។

ប៉ុន្តែកិច្ចការប្រទេសជាតិស្ថិតនៅក្នុងដៃមន្ត្រីយួន។ ទីក្រុងភ្នំពេញនិងខេត្តត្រូវប្ដូរឈ្មោះទៅជាឈ្មោះយួនវិញ។ យួនបង្ខំអោយមន្ត្រីខ្មែរស្លៀកពាក់និងធ្វើតាមទំលាប់រាជវាំងក្រុងវេ។ យួនប្រឆាំងនឹងព្រះពុទ្ធសាសនាខ្មែរ (ហីនយាន) កាប់រំលំដើមពោធិ៍ គាស់រំលើងចេតិយ បណ្ដេញព្រះសង្ឃចេញពីវត្ត វាយកំទេចព្រះពុទ្ធរូប ហើយសំលាប់នាម៉ឺនណា ដែលបានជួយសៀម។ ទ័ពយួននៅត្រួតត្រាប្រទេសខ្មែរ សង្កត់សង្កិនប្រជារាស្ត្រខ្មែរ ដែលបន់ស្រន់សុំអោយព្រះអង្គម្ចាស់អង្គអិម និងអង្គឌួង វិលត្រលប់មកពីបាត់ដំបងវិញ។ មេទ័ពយួនដឹងរឿងនេះ ក៏ប្រើផែនការក្បត់។ អង្គអិមត្រូវយួនចាប់បានរួចបញ្ជូនទៅព្រៃនគរ ចំណែកឯព្រះអង្គឌួងត្រូវសៀមចាប់យកទៅទុកនៅទីក្រុងបាងកក។ នៅចំពោះការធ្វើបាបគ្រប់បែបយ៉ាងទាំងនេះ ប្រជារាស្ត្រខ្មែរងើបបះបោរឡើង។ នាម៉ឺនខ្មែរធំៗបានសុំជំនួយពីសៀម។ មេទ័ពសៀម ពញាបឌិនតេជោលើកទ័ពចូលមកបណ្ដេញយួន ហើយនាំព្រះអង្គឌួងចូលមកក្រុងឧដុង្គ។ ព្រះអង្គឌួងបានត្រូវប្រជារាស្ត្រអបអរសាទរទទួលជាព្រះមហាក្សត្រនាឆ្នាំ១៨៤០ : នៅទីបំផុត ប្រទេសខ្មែរមានមហាក្សត្រធំមួយអង្គឡើងវិញហើយ។



ប្រជារាស្ត្រខ្មែរបះបោរប្រឆាំងនឹងពួកយួន។

### សាកល្បងរកចំលើយ

ស្ដេចយួននាមមិញម៉ាង បានបង្ខំអោយក្សត្រីអង្គម៉ីឡើងសោយរាជ្យបន្តពីព្រះបិតាគឺព្រះអង្គចន្ទទី២ ពីព្រោះ

ក-អង្គម៉ីជាអ្នកខ្លាំងពូកែ ?
ខ-អង្គម៉ីជាក្សត្រីវៃឆ្លាត ?
គ-អង្គម៉ីអាចធ្វើជាឡប់ខ្សែ ដើម្បីអោយយួនងាយត្រួតត្រាខ្មែរ ?

ចំលើយ : ទំព័រ៤៤

# អង្គឌួង-របត់មួយនៃប្រវត្តិសាស្ត្រខ្មែរ

១៨៤០-១៨៥៩



ព្រះបាទអង្គឌួង

ព្រះបាទអង្គឌួង ដែលជារាជបុត្រពៅរបស់ព្រះបាទអង្គអេង បានធ្វើអោយរាជានិយមខ្មែររុងរឿងឡើងវិញ។ ព្រះអង្គមានព្រះទ័យព្រួយខ្វល់ខ្វាយខ្លាំងនឹងការបាត់បង់ទឹកដី។ ពេលទ្រង់ជ្រាបថា បារាំងចូលមកតាំងនៅសិង្ហបុរីហើយនោះ ព្រះអង្គក៏បានទៅសុំការគាំទ្រពីបារាំង តែទ្រង់ពុំបានទទួលជោគជ័យទេ។

### ▶ ព្រះអង្គឌួង និងកំណែសង្គមកិច្ច

ព្រះបាទអង្គឌួងជាសម្ព័ន្ធមិត្តនឹងសៀម។ ឥលូវដល់ពេលដែលព្រះអង្គត្រូវរំដោះកម្ពុជាចេញពីឥទ្ធិពលយួនហើយ។ ជ័យជំនះជាច្រើនកន្លែងនៅឧដុង្គនិងលង្វែក បានផ្តល់អំណាចអោយទ្រង់ជជែកជាមួយពួកយួន : គេបានប្តូរឈ្លើយសឹកទៅវិញទៅមក។ ព្រះបាទអង្គឌួង បានទទួលរាជាភិសេកនៅឧដុង្គ (១៨៤៧) ប៉ុន្តែក្រោមការឧបត្ថម្ភពីយួននិងសៀម។ ការបែកបាក់គ្នាជាច្រើនសតវត្ស និងចំបាំងឈ្លានពានរបស់បរទេស បានធ្វើអោយប្រទេសជាតិវិនាសហិនហោច។ ព្រះអង្គឌួងបានរៀបចំអោយប្រទេសជាតិមានសន្តិភាព និងអោយរាជការមានរបៀបរៀបរយឡើងវិញ។ ទ្រង់ជាក្សត្រស្លូតត្រង់ យុត្តិធម៌ មានព្រះទ័យល្អ និងកាន់ពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន។ ទ្រង់ធ្វើអោយជីវភាពប្រជារាស្ត្របានប្រសើរ។ ព្រះអង្គបន្ថយពន្ធអាករ មិនអោយកែនអ្វីទាំងអស់នៅវេលាធ្វើស្រែចំការ និងបរិច្ចាគព្រះរាជទ្រព្យផ្ទាល់ ដើម្បីលោះមនុស្សខ្ញុំគេអោយបានរួចខ្លួន។ ទ្រង់បានដាក់ទណ្ឌកម្មលើអ្នកប្រមឹក អ្នកជក់អាភៀន និងអ្នកលេងល្បែងស៊ីសង។ ទ្រង់បានកសាងវត្តអារាមជាច្រើន ពង្រីកការសិក្សា កសាងផ្លូវស្ពាន ស្ថាបនាព្រះរាជវាំងនៅឧដុង្គឡើងវិញ បោះប្រាក់អោយរាស្ត្រប្រើប្រាស់។ ព្រះអង្គបានអោយលើកផ្លូវពីឧដុង្គទៅកំពតដែលជាកំពង់ផែសមុទ្រតែមួយរបស់ខ្មែរ និងផ្លូវពីឧដុង្គទៅកំពង់ហ្លួងដែលជាកំពង់ផែទន្លេសំខាន់ណាស់នៅសម័យនោះ។

#### កំណែរដ្ឋបាល

ព្រះអង្គឌួងបានកាត់បន្ថយចំនួនខេត្តនៃព្រះរាជនគរ ហើយដាក់ចៅហ្វាយខេត្តអោយនៅក្រោមរដ្ឋបាលកណ្តាលរបស់ព្រះអង្គច្រើនជាងមុន។

#### សំណព្វដឹងទេថា

ព្រះអង្គឌួង ជាអ្នកនិពន្ធខ្មែរយ៉ាងល្បីល្បាញ។ ទ្រង់បានទុកស្នាព្រះហស្តអោយកូនចៅជំនាន់ក្រោយ ដូចជា រឿងកាកី (គ.ស.១៨១៥) ច្បាប់ស្រី (គ.ស.១៨៣៧) ជាដើម។



សាស្ត្រាស្លឹករឹត



ប្រាក់ប្រាសាទ ទម្ងន់៤ជី (១៥ក្រាម) អង្កត់ផ្ចិត ៣៥មម បោះក្នុងរជ្ជកាលព្រះបាទអង្គឌួង។

### ▶ អង្គឌួង និងការអំពាវនាវចំពោះប្រទេសបារាំង

ប៉ុន្តែពេលនោះ សៀមប្រុងប្រៀបរឹបអូសយកខេត្តបាត់ដំបងនិងអង្គរ ហើយប្រហែលចង់យកខេត្តម្លូព្រៃ និងទន្លេរពៅទៀតផង : ចៅហ្វាយខេត្តគ្រប់គ្រងខេត្តទាំងនេះគិតថាខ្លួនគេជាចំណុះរបស់សៀម ហើយបញ្ជូនពន្ធដារឡើងទៅសៀម។ ឯក្សត្រខ្មែរ ដែលរស់នៅបាងកក ក៏យល់ព្រមទទួលស្គាល់ស្តេចសៀមជាមហារាជផងដែរ។ ចំណែកយួនចេះតែបន្តត្រួតត្រាផ្ទាល់ទៅលើខេត្តជាច្រើននៃទឹកដីកម្ពុជាក្រោម។ ក្នុងអាណាខេត្តទាំងនោះ យួនបំផ្លាញចោលអ្វីៗជាអត្តសញ្ញាណខ្មែរ ដែលធ្វើអោយប្រជាជនខ្មែរត្រូវរត់គេចមកជ្រកកោនជារឿយៗ នៅកម្ពុជាលើ។ ដើម្បីបញ្ឈប់ការរំលោភយកទឹកដីខ្មែរពីសំណាក់សៀមពីខាងលិច និងយួនពីខាងកើត ទ្រង់ក៏សំរេចព្រះទ័យអំពាវនាវសុំជំនួយពីប្រទេសបារាំង (នៅឆ្នាំ១៨៥៤ ទ្រង់ផ្ញើព្រះលិខិតទៅថ្វាយអធិរាជបារាំង ព្រះចៅណាប៉ូឡេអុងទី៣)។ ប៉ុន្តែសៀមដឹងពីការស្នើសុំនេះ : លោកដឺម៉ុង ទីញី ដែលជារាជទូតបារាំងបានធ្វើអោយខូចការដោយប្រាប់ពត៌មានអំពីរឿងនេះអោយសៀមដឹង។ សៀមគំរាមកំហែងព្រះអង្គឌួងអោយឈប់ទាក់ទងនឹងបារាំង ហើយព្រះមហាក្សត្រលែងហ៊ានទទូចទៀតទៅ។

#### ខិតខំរៀងខ្លួន

- ពួកយួននៅក្នុងអាណាខេត្តដែលខ្លួនដណ្តើមយកបានបានតែងតាំងបុគ្គលិកនិងរដ្ឋបាលយួនជំនួសបុគ្គលិកនិងរដ្ឋបាលខ្មែរទាំងស្រុង។
- ពួកសៀម រិះរកគ្រប់មធ្យោបាយដើម្បីបញ្ចុះបញ្ចូលខ្មែរ ដែលរស់នៅក្នុងខេត្តដែលសៀមចង់បាន អោយជឿជាក់ថានឹងទទួលបានអត្ថប្រយោជន៍ច្រើនពីអាណាព្យាបាលរបស់សៀម។

#### ដោះខ្លួនយ៉ាងប៉ិនប្រសប់ !

សៀមបានផ្ញើលិខិតសុំអោយមានការទទួលស្គាល់ថា ខេត្តម្លូព្រៃ និងទន្លេរពៅ ជារបស់សៀម។ ព្រះអង្គឌួងទ្រង់ព្រះលិខិតតបវិញថា «ខ្ញុំមិនអោយអ្វីទាំងអស់ទៅសៀមឡើយ តែដោយសារពេលនេះសៀមមានកំលាំងខ្លាំងជាងសៀមអាចបន្តកាន់កាប់ជាបណ្តោះអាសន្ននូវអ្វីៗ ដែលខ្លួនបានរឹបយកពីកម្ពុជា»។

# នរោត្តម-ការដាក់អាណាព្យាបាលបារាំង

## ១៨៥៩-១៩០៤





ព្រះបាទ នរោត្តម បុត្រាច្បងព្រះបាទអង្គឌួង បានស្នងរាជ្យបន្តពីព្រះបិតានៅឆ្នាំ១៨៥៩។ ដើម្បីមានបង្អែកទប់ទល់នឹងឥទ្ធិពលសៀមនិងយួន ទ្រង់បានចុះព្រះហស្តលេខាលើសន្ធិសញ្ញា ឆ្នាំ១៨៦៣ជាមួយបារាំង ដែលទើបនឹងចូលមកយកដែនដីកូសាំងស៊ីនធ្វើជាអាណានិគម(១៨៦២)។

### ▶ ព្រះបាទ នរោត្តម

នាយទាហានជើងទឹក និងអ្នកប្រាជ្ញបារាំងខ្លះៗ បានចូលមកមើលកម្ពុជា។ ការនិទានដោយកោតសរសើររបស់ពួកគេធ្វើអោយមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ ឧត្តមនាវីឡាក្រង់ឌៀ ដែលជាទេសាភិបាលបារាំងនៅកូសាំងស៊ីន បានបញ្ជូននាយទាហានឈ្មោះ ឌូដាជីឡាក្រេ មកក្រាបទូលព្រះបាទនរោត្តម អោយទ្រង់ទទួលយកអាណាព្យាបាលបារាំង។ ទោះបីជាសៀមរារាំងយ៉ាងណាក្តី ក៏ព្រះអង្គទទួលយល់ព្រមដែរ(សន្ធិ-សញ្ញា១៨៦៣)។ នៅសម័យនោះ កំណែទំរង់របស់ព្រះបាទអង្គឌួងទើបនឹងចាប់ផ្តើមប៉ុណ្ណោះ។ សៀមនិងយួនមានមុខនៅកម្ពុជានៅឡើយ។ ម្យ៉ាងទៀតព្រះអង្គម្ចាស់ស៊ីវត្ថា អនុជរបស់ព្រះរាជា បានចេញពីវាំងទៅបំបះបំបោររាស្ត្រ រាតត្បាតត្រើយខាងកើតទន្លេមេគង្គរួចវាយយកបានក្រុងភ្នំពេញ។ ព្រះបាទនរោត្តមត្រូវភៀសព្រះអង្គទៅគង់នៅបាត់ដំបងមួយរយៈ។ ចំពោះមុខការលំបាកអស់នេះ ទើបព្រះបាទនរោត្តមព្រមទទួលយកជំនួយពីបារាំង។ ការបះបោរត្រូវបានបង្ក្រាបទៅវិញ។ អនុជមួយអង្គទៀតព្រះនាមស៊ីសុវត្ថិ មានតួនាទីសំខាន់ក្នុងការធ្វើអោយប្រទេសមានរបៀបរៀបរយឡើងវិញ។

ព្រះបាទនរោត្តម
និងព្រះហស្តលេខា

### សំណាញ់នឹងទេថា

ភ្នំពេញនាឆ្នាំ១៨៦៧ ជាមជ្ឈ-មណ្ឌលពាណិជ្ជកម្មមានប្រជា-ជនប្រហែល ១០ ០០០នាក់ ភាគច្រើនជាចិន។ បើគេគិតទាំងអ្នករស់នៅលើទឹកផង ប្រជាជនសរុបនៃក្រុងភ្នំពេញមានប្រមាណ ៣០ ០០០នាក់។



### ▶ អាណាព្យាបាលបារាំងដំបូង

សៀមបានបញ្ជូនមកុដនិងព្រះខាន់រាជ្យមកឧដុង្គវិញ ព្រះរាជាខ្មែរទទួលរាជាភិសេកនៅក្រុងនេះ ក្នុងឆ្នាំ១៨៦៤។ ដូចនេះអធិរាជភាពសៀមនិងវៀតណាម ដែលធ្វើអោយកម្ពុជារងទុក្ខវេទនានោះ រលាយបាត់ហើយ។ រាជធានីត្រូវលើកពីឧដុង្គមកតាំងនៅភ្នំពេញវិញនៅឆ្នាំ១៨៦៧។ ប៉ុន្តែបារាំងមិនប្រគល់ដែនដីកម្ពុជាក្រោមមកអោយខ្មែរវិញទេ។ បារាំងថែមទាំងបណ្តោយអោយសៀមយកខេត្តខ្មែរពីរទៀតផងគឺ បាត់ដំបងនិងអង្គរនៅឆ្នាំ១៨៦៧។ ព្រះបាទនរោត្តមរៀបចំនគរឡើងវិញបន្តពីព្រះបិតា។

### ▶ អាណាព្យាបាលប្រើអំណាច

បារាំងបង្ខំខ្មែរអោយទទួលយកបញ្ញត្តិថ្មីៗជាច្រើនទៀតយកគំរូតាមច្បាប់អឺរ៉ុប ដែលគ្មានលំនាំស្របតាមទំនៀមទំលាប់របស់ខ្មែរឡើយ។ ទេសា-ភិបាលបារាំង សាល ថុំសុន បង្ខំព្រះរាជាអោយឡាយព្រះហស្តលេខាលើអនុសញ្ញាឆ្នាំ១៨៨៤ ដែលពង្រីកការត្រួតត្រារបស់បារាំង និងដកសិទ្ធិអំណាចសឹងតែទាំងស្រុងពីព្រះរាជានិងមន្ត្រីខ្មែរ។ អ្នកស្នេហាជាតិក្រោកឡើងកាន់អាវុធប្រឆាំងនៅទូទាំងប្រទេស។ នៅឆ្នាំ១៨៩៧ ដោយការប្រើកំលាំងនិងការគំរាមកំហែងដែរ បារាំងដកហូតពីព្រះរាជានូវសិទ្ធិអំណាចដែលនៅសល់។ ព្រះអង្គម្ចាស់យុគន្ធរ បុត្រាព្រះបាទនរោត្តម យាងទៅធ្វើការតវ៉ាប្រឆាំងនៅប្រទេសបារាំង(១៩០០) តែពុំបានលទ្ធផលឡើយ។ ក្រោយមក អ្វីៗត្រូវបានសំរុះសំរួល។ ប៉ុន្តែការការពាររបស់បារាំងក្លាយទៅជាអាណាព្យាបាល ដែលប្រើអំណាច។

### ឡាយព្រះហស្តលេខាដោយត្រូវចាប់បង្ខំ

ទេសាភិបាលបារាំង(សាល ថុំសុន) ទូលថា «ព្រះអង្គត្រូវជ្រើសរើស : ឡាយព្រះហស្ត-លេខា រឺដាក់រាជ្យ។ សូមទ្រង់សំរេច។» -«ចុះបើយើងមិនឡាយ និងមិនដាក់រាជ្យ?»។ ទេសាភិបាលចង្អុលទៅនាវាចំបាំង ដែលបោះយុថ្កានៅមុខវាំង រួចទូលថា «សូមទ្រង់ទតមើលផ្សែងនោះ នាវាឈ្មោះអាល្វអែតបញ្ឆេះម៉ាស៊ីនប្រុងចេញដំណើរហើយ។ មិនព្រមឡាយ គឺត្រូវចាប់យកដាក់ក្នុងនាវា រួចបើកចេញទៅ...»។ ព្រះអង្គឱនចុះ រួចឡាយព្រះហស្តដោយព្រះទ័យក្រៀមក្រំនិងសោកស្តាយក្រៃលែង។

១ ស្ពានឥន្ទធនូ(ស្ពានថាប) ឆ្លងព្រែកពោធិ៍ពាយ។
២ វត្តភ្នំមើលពីស្ពាននាគ។
៣ ព្រះរាជវាំងធ្វើពីឈើសាងសង់នៅឆ្នាំ១៨៦៦។


១


២


៣

# ស៊ីសុវត្ថិ ១៩០៤-១៩២៧ និង មុនីវង្ស ១៩២៧-១៩៤១
# ការបន្តអនុសញ្ញាបារាំង-ខ្មែរឆ្នាំ១៨៨៤



ព្រះបាទស៊ីសុវត្ថិ (អនុជព្រះបាទនរោត្តម) និងព្រះបុត្រាមុនីវង្ស ជាជំនួយការរបស់ព្រះអង្គ។

បន្ទាប់ពីព្រះបាទនរោត្តម ព្រះបាទស៊ីសុវត្ថិនិងស៊ីសុវត្ថិមុនីវង្ស បានសោយរាជ្យជាបន្តបន្ទាប់។ សៀមបានប្រគល់ខេត្តម្លូព្រៃ និងទន្លេរពៅមកវិញនៅឆ្នាំ១៩០៤។ ឯខេត្តបាត់ដំបង និងអង្គរ ក៏បានមកកម្ពុជាវិញដែរ នៅឆ្នាំ១៩០៧ (ផែនទីទំព័រ៤៣,ក)។ ព្រះនគរបានស្គាល់សន្តិភាពហើយ។

## ? សាកល្បងរកចំលើយ

ស្ពានព្រះមុនីវង្ស (២៩២ម) សម្ពោធអោយប្រើនៅខែវិច្ឆិកា ១៩២៨។ ស្ពាននោះឆ្លងកាត់

ក-ទន្លេមេគង្គ ?

ខ-ទន្លេបាសាក់ ?

គ-ទន្លេសាប ?

ចំលើយ : ទំព័រ៤៤



### ▶ ការងារទំនើបកម្មបានចាប់ផ្តើម...

**កសិកម្ម :** ក្នុងរជ្ជកាលព្រះរាជាទាំងពីរអង្គនេះ មានការរីកចំរើនខាងកសិកម្ម និងការបង្កើតចំការកៅស៊ូធំៗ។ គេរើសសំរាំងយកពូជដំណាំ ពំរូវនឹងលក្ខណៈប្រទេស។ បន្ទាប់មក កម្ពុជាអាចនាំយកស្រូវចេញទៅលក់ឯក្រៅប្រទេស។ បសុពេទ្យប្រយុទ្ធនិងជំងឺ ដែលសំលាប់គោក្របី។

**សុខភាព :** គេក៏យកចិត្តទុកដាក់ចំពោះសុខភាពប្រជាជនផងដែរ។ នៅឆ្នាំ១៨៨៥ គេបានបង្កើតផ្នែកពេទ្យសំរាប់ព្យាបាលជំងឺជូនអ្នកស្រុក។ ផ្នែកនេះរីកចំរើនបន្តិចម្តងៗពីភ្នំពេញរហូតទៅដល់ខេត្តឆ្ងាយៗ។ មានផ្នែកព្យាបាលជំងឺ និងផ្នែកចាក់ថ្នាំបង្ការរោគ ដូចជាបង្ការរោគអុតជាដើម។

**វប្បធម៌ និងសិល្បៈ :** កម្ពុជាខិតខំស្វែងរកអតីតកាលរបស់ខ្លួនឡើងវិញ។ គេខិតខំជួសជុលប្រាង្គប្រាសាទអង្គរ ដែលជាសក្ខីភាពសេសសល់ពីភាពរុងរឿងនៃសម័យអង្គរ។ គេបានសាងសារមន្ទីរជាតិ សាលាបាលីជាន់ខ្ពស់ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងសាលាសិល្បៈខ្មែរ។

**ការសិក្សាអប់រំ :** ការសិក្សាចំណេះទូទៅបានទទួលអាទិភាពជាពិសេស។ ការសិក្សាទំនើបចាប់កើតឡើងហើយ។ គេបង្កើតសាលាបឋមសិក្សាបារាំងនៅតាមឃុំនិងកែប្រែសាលាវត្តអោយបង្រៀនតាមបែបទំនើប។ នៅភ្នំពេញមានបង្កើតអនុវិទ្យាល័យស៊ីសុវត្ថិនៅឆ្នាំ១៩០៤។

### ▶ ...តែនៅខ្វះខាតច្រើន

**ការអភិវឌ្ឍនៅទន់ខ្សោយ :** តាមពិតកម្ពុជាមិនមែនជារដ្ឋស្វយ័តទេ។ កម្ពុជាគ្រាន់តែជាផ្នែកមួយរបស់សហភាពឥណ្ឌូចិន ដែលបង្កើតនៅឆ្នាំ១៨៨៧ ហើយមានប្រទេស៥ : តុងកឹង អណ្ណាម កូសាំងស៊ីន លាវ និងកម្ពុជា។ នៅក្នុងសហភាពឥណ្ឌូចិននេះ បារាំងទុកកម្ពុជាជាប្រទេសកសិកម្ម ដូចនេះមិនបាច់មានឧស្សាហកម្មទេ។ ឯកទេសផ្នែកនេះត្រូវទុកអោយប្រទេសផ្សេងៗមាន តុងកឹង អណ្ណាម និងកូសាំងស៊ីន។

**ត្រៀមខ្លួនមិនបានល្អដើម្បីទទួលឯករាជ្យ :** ដោយការអភិវឌ្ឍតិចតួចដូចនេះ កម្ពុជាមិនបានរៀបចំខ្លួនដើម្បីឯករាជ្យឡើយ។ សេចក្តីសំរេចនានាត្រូវចេញពីក្រុងព្រៃនគរ ដែលជាទីស្នាក់ការកណ្តាលរបស់រដ្ឋ-បាលសហភាព។ កម្ពុជាមានរបបរាជានិយមជ្រើសរើស ដោយមានរ៉េស៊ីដង់ជាតិបារាំងម្នាក់ជាអ្នកត្រួតពិនិត្យ។ ព្រះមហាក្សត្រនិងសភាពុំមានអំណាចពិតប្រាកដអ្វីឡើយ។



ចំការកៅស៊ូ







ក្រដាសប្រាក់ឥណ្ឌូចិន ១៩៣៩

**សាលាវត្តបែបថ្មីសំរាប់អប់រំនៅជនបទ**

វត្តអារាមនៅតែជាកន្លែងអប់រំដដែល។ នៅបណ្តាឆ្នាំ១៩៤០ គេបានរៀបចំអោយវត្តមួយចំនួនធំមានសាលាបឋមសិក្សា ដែលអនុវត្តកម្មវិធីសិក្សាផ្លូវការរបស់រដ្ឋ ប៉ុន្តែគ្រូបង្រៀនភាគច្រើនជាព្រះសង្ឃ ដែលបានទទួលការបណ្តុះបណ្តាលតិចតួចពីរដ្ឋ។ កុមារី ក៏អាចចូលទៅរៀនបានដែរ។

នៅសម័យនោះ មានកើតសង្គ្រាមលោកលើកទី១(១៩១៤-១៩១៨)។ គេច្បាំងគ្នានៅទ្វីបអឺរ៉ុប។ អ្នកស្ម័គ្រចិត្តខ្មែរមួយចំនួន ក្នុងនោះមានព្រះអង្គម្ចាស់៦អង្គ បាននៅជួយបារាំងច្បាំងនឹងអាឡឺម៉ង់។

# នរោត្តមសីហនុវរ្ម័ន-ព្រះបិតាឯករាជ្យជាតិ

## រជ្ជកាលទី១ : ១៩៤១-១៩៥៥



ព្រះបាទនរោត្តមសីហនុវរ្ម័ន
ក្នុងព្រះជន្ម១៩វស្សា

**ព្រះបាទនរោត្តមសីហនុវរ្ម័នទ្រង់បានឡើងសោយរាជ្យនៅឆ្នាំ១៩៤១។ ព្រះអង្គបានទាមទារឯករាជ្យពីបារាំងជូនជាតិរហូតបានពេញលេញនៅឆ្នាំ១៩៥៣។**

### ▶ ព្រះរាជាឡើងគ្រងរាជ្យនៅក្នុងពេលមានសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥)

នៅឆ្នាំ១៩៣៩ សង្គ្រាមលោកលើកទី២បានផ្ទុះឡើងនៅអឺរ៉ុប រវាងភាគីម្ខាងគឺបារាំងនិងអង់គ្លេស និងម្ខាងទៀតគឺអាឡឺម៉ង់។ នៅអាស៊ី ជប៉ុនគាំទ្រអាឡឺម៉ង់។ ប្រទេសបារាំងទទួលបរាជ័យ ហើយរក្សាអំណាចបានតែសំបកក្រៅ។ ជប៉ុនបានពង្រឹងអំណាចខ្លួននៅអាស៊ី។ កងទ័ពជប៉ុនបានចូលរាតត្បាតពាសពេញឥណ្ឌូចិន ហើយចូលមកកម្ពុជានៅឆ្នាំ១៩៤១។ ឆ្លៀតឱកាសនោះ ថៃដែលមានជប៉ុនគាំទ្រ បានរឹបអូសយកខេត្តបាត់ដំបង ខេត្តសៀមរាបមួយភាគ កំពង់ធំមួយភាគនិងស្ទឹងត្រែងមួយភាគ (ផែនទីទំព័រ៤៣,១)។ ព្រះមុនីវង្សសុគតនៅឆ្នាំ១៩៤១ ក្នុងព្រះទ័យក្រៀមក្រំដោយបរាជ័យរបស់បារាំង ដែលជាអាណាព្យាបាលមិនបានបំពេញតាមពាក្យសន្យា។ ព្រះអង្គម្ចាស់សីហនុឡើងគ្រងរាជ្យបន្ត។ ជប៉ុនបានចាប់បារាំងឃុំឃាំង ហើយនៅខែមីនាឆ្នាំ១៩៤៥ បានប្រគល់ឯករាជ្យអោយកម្ពុជា។ នៅឆ្នាំ១៩៤៥នោះដែរ ជប៉ុនបរាជ័យ ដកកងទ័ពចេញពីកម្ពុជា ហើយបារាំងបានវិលត្រលប់មកវិញ។ ថៃបានប្រគល់ទឹកដី ដែលគេបានរឹបអូសកាលពីឆ្នាំ១៩៤១ មកអោយខ្មែរវិញ។ ប៉ុន្តែស្ថានភាពរបស់បារាំងចុះខ្សោយណាស់ទៅហើយ។ ប្រទេសកម្ពុជាចង់បានឯករាជ្យ។ ខ្មែរឥស្សរៈ (ចលនារំដោះជាតិ) បានកើតឡើងជាច្រើនក្រុម។ ក្រុមខ្លះចងសម្ព័ន្ធភាពជាមួយវៀតមិញ (ចលនាឯករាជ្យវៀតណាម) ដើម្បីធ្វើចំបាំងប្រឆាំងនឹងបារាំង។

**សំណាញ់និងមេធា**

ព្រះបាទនរោត្តមសីហនុវរ្ម័នជារាជបុត្រាព្រះបាទនរោត្តមសុរាម្រឹត និងព្រះមហាក្សត្រិយានីស៊ីសុវត្ថិមុនីវង្ស កុសុមនារីរត្នសិរីវឌ្ឍនា។ ទ្រង់ឡើងគ្រងរាជ្យ នៅឆ្នាំ១៩៤១ ក្នុងព្រះជន្មាយុ១៩ព្រះវស្សា។



### ▶ ឯករាជ្យរបស់កម្ពុជា



កងកំលាំងជីវពល ក្នុងព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ

ឯករាជ្យជាតិជាស្នាព្រះហស្ថរបស់ព្រះបាទនរោត្តមសីហនុវរ្ម័ន។ សកម្មភាពទូតរបស់ទ្រង់នៅប្រទេសបារាំង អាមេរិច កាណាដា និង ជប៉ុន មានសារៈសំខាន់ខ្លាំងណាស់។ ការលំបាកធំបំផុតនោះ គឺមកពីសង្គ្រាមនៅវៀតណាម ដែលពួកវៀតមិញធ្វើការប្រយុទ្ធដើម្បីបង្កើតរបបកុំមុយនីសផង និងដើម្បីរកឯករាជ្យអោយប្រទេសវៀតណាមផង។ គេបារម្ភក្រែងឥណ្ឌូចិនទាំងមូលនឹងក្លាយទៅជាប្រទេសកុំមុយនីស។ ប្រទេសចិននិងរុស្ស៊ីបានទៅជាកុំមុនីសរួចហើយ។ អាមេរិចនិងបារាំងមានការភ័យខ្លាច។ ប្លុកទាំងពីរ គឺប្លុកសេរីនិងប្លុកកុំ-មុយនីស ប្រឈមមុខដាក់គ្នានៅទូទាំងពិភពលោក នៅក្នុងសង្គ្រាមមួយដែលគេហៅថាសង្គ្រាមត្រជាក់ (គឺសង្គ្រាមមនោគមវិជ្ជារវាងប្លុកសេរីនិងប្លុកកុំមុយនីស)។ ជំលោះដ៏សែនគ្រោះថ្នាក់នេះអាចអូសទាញកម្ពុជាអោយចូលទៅក្នុងប្លុកខាងនេះ រឺប្លុកខាងនោះ។ ក្រោយពីមានការអលអែកនិងការចរចាជាច្រើនលើកច្រើនសាមក បារាំងក៏បានប្រគល់ឯករាជ្យអោយកម្ពុជានៅថ្ងៃទី៩ វិច្ឆិកា ឆ្នាំ១៩៥៣ រួចព្រះបាទនរោត្តមសីហនុវរ្ម័នប្រកាសព្រះរាជាណាចក្រកម្ពុជាជាប្រទេសអព្យាក្រឹត គឺមិនចូលប្លុកខាងណាឡើយ។

**ប្រតិបត្តិការ «សាមគ្គី»**

ខែធ្នូ ឆ្នាំ១៩៥៣ ព្រះបាទនរោត្តមសីហនុវរ្ម័ន បានដឹកនាំប្រតិបត្តិការសឹក«សាមគ្គី» ដើម្បីបណ្តេញពួកវៀតមិញចេញពីខេត្តបាត់ដំបង។ ប្រតិបត្តិការនោះទទួលបានជ័យជំនះ។

ប្រតិបត្តិការសឹក«សាមគ្គី» នៅបន្ទាយកន្ទី ខេត្តបាត់ដំបង



**កាលបរិច្ឆេទខ្លះៗ**

- ▶ ១៩៤៥ ជប៉ុនដកទ័ពចេញពីកម្ពុជា។
- ▶ ១៩៤៦ ថៃប្រគល់ទឹកដីរឹបអូសយកនៅឆ្នាំ១៩៤១ មកអោយខ្មែរវិញ។
- ▶ ១៩៤៧ ព្រះបាទសីហនុវរ្ម័ន ប្រទានរដ្ឋធម្មនុញ្ញទី១។
- ▶ ១៩៤៩ បារាំងប្រគល់ឯករាជ្យមិនពេញលេញអោយខ្មែរ។
- ▶ ពាក្កដា ១៩៥១ កម្ពុជាចូលជាសមាជិកអង្គការយូណេស្កូ។
- ▶ ១៤ ធ្នូ ១៩៥៥ កម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ។
- ▶ មិថុនា ១៩៦២ តុលាការអន្តរជាតិក្រុងឡាអេ សំរេចអោយប្រទេសថៃប្រគល់ប្រាសាទព្រះវិហារមកខ្មែរវិញ។



ព្រះបាទសុរាម្រឹត និង
ព្រះមហាក្សត្រិយានី

## សុរាម្រិត-ព្រះរាជាព្រះទ័យល្អ

ព្រះបាទ នរោត្តមសុរាម្រឹត បានគ្រងរាជ្យពីឆ្នាំ១៩៥៥ដល់ឆ្នាំ១៩៦០។ ព្រះអង្គស្មោះត្រង់ ស្រលាញ់អ្នកដទៃ ការពាររាស្ត្រតូចតាច ពូកែផ្សះផ្សាជំលោះ ទទួលរាស្ត្រ ដែលគិតថាខ្លួនជាអ្នករងគ្រោះអោយចូលជួបធ្វើសវនាការសុំជួយរកយុត្តិធម៌។

## សាកល្បងរកចំលើយ

វិទ្យាល័យព្រះសីហនុស្ថិតនៅក្នុង

ក-ខេត្តកំពង់ចាម ?
ខ-ខេត្តកណ្តាល ?
គ-ក្រុងភ្នំពេញ ?

ចំលើយ : ទំព័រ៤៤



## ▶ កម្ពុជាក្នុងសង្គ្រាមត្រជាក់

ចាប់ពីឆ្នាំ១៩៤៧ ព្រះមហាក្សត្របានផ្លូវរបបរាជានិយមផ្តាច់ការមករាជានិយមអាស្រ័យរដ្ឋធមនុញ្ញវិញ។ ក្រោយពីដឹកនាំរាជាណាចក្រអោយបានឯករាជ្យនិងសន្តិភាពហើយ ព្រះបាទនរោត្តមសីហនុវ័រ្មនបានដាក់រាជ្យនៅខែមីនាឆ្នាំ១៩៥៥។ ទ្រង់ថ្វាយរាជសម្បត្តិទៅព្រះបិតា គឺព្រះបាទនរោត្តមសុរាម្រិត ហើយទ្រង់ទទួលព្រះគោរមងារជា «សម្តេចព្រះឧបយុវរាជ» ឯប្រជារាស្ត្រថ្វាយព្រះនាមថា «សម្តេចឪ»។ ដើម្បីបង្រួបបង្រួមអ្នកនយោបាយខ្មែរ ទ្រង់បានបង្កើតចលនាសង្គមរាស្ត្រនិយម។ ស្ថិតនៅក្រោមការដឹកនាំរបស់ព្រះអង្គ ចលនានេះបានធ្វើអោយប្រទេសទំនើបឡើង : ឧស្សាហកម្មមានការជឿនលឿន កំពង់ផែសមុទ្រធំមួយបានត្រូវសាងសង់នៅទីក្រុងព្រះសីហនុ...។ ប៉ុន្តែសង្គ្រាមត្រជាក់ចេះតែបន្ត ហើយនៅតាមព្រំដែនខ្មែរ សង្គ្រាមវៀតណាមឆាបឆេះកាន់តែខ្លាំងឡើងៗ។ មហាអំណាចនីមួយៗចេះតែរកឧបាយអូសទាញកម្ពុជាអោយចាកចេញពីអព្យាក្រឹតភាពរបស់ខ្លួន ជាថ្នូរនឹងជំនួយរបស់គេ។ គ្រោះថ្នាក់មានទំហំធំសំបើម។ ក្នុងមនោគមវិជ្ជាផ្ទុយគ្នានេះ ប្រទេសកម្ពុជា ដែលជា«កោះសន្តិភាព» អាចលង់ខ្លួនទៅក្នុងសង្គ្រាមបរទេស រឺសង្គ្រាមក្នុងស្រុក ដែលនឹងនាំមកនូវក្តីវេទនា ការឈឺចាប់ ការបាត់បង់អាយុជីវិត និងវិនាសកម្មគ្រប់បែបយ៉ាង។

កំពង់ផែព្រះសីហនុកំពុងសាងសង់ (ឆ្នាំ១៩៥៨)។ កំពង់ផែនេះបានត្រូវសម្ពោធអោយប្រើជាផ្លូវការនៅឆ្នាំ១៩៦០។





### វិមានឯករាជ្យ

- ▶ កសាងនៅឆ្នាំ១៩៥៨តាមព្រះរាជតំរិះរបស់សម្តេចព្រះឧបយុវរាជ ដើម្បីរំលឹកវិញ្ញាណក្ខន្ធយុទ្ធជនអ្នកស្នេហាជាតិ។
- ▶ ស្ថាបត្យករ លោក វណ្ណ ម៉ូលីវណ្ណ។
- ▶ ក្បាលនាគសរុបមាន១០០។

វិមានឯករាជ្យ ក្នុងឱកាសបុណ្យរំលឹកឯករាជ្យខួបទី៥០ (ឆ្នាំ២០០៣)



# ការរកឃើញឡើងវិញ និងការជួសជុលអង្គរ

ពួកអ្នកផ្សាយសាសនា នៅពីមុខអង្គរវត្ត

**សាលាបារាំងចុងបូព៌ាប្រទេស**
ជាស្ថាប័នបង្កើតឡើងនៅឆ្នាំ១៨៩៨ មានភារកិច្ចថែរក្សាការពារសម្បត្តិវប្បធម៌នៅឥណ្ឌូចិន។

**អភិរក្សដ្ឋានអង្គរ**
ជាស្ថាប័នបង្កើតឡើងនៅឆ្នាំ១៩០៧ សំរាប់រក្សាទុកវត្ថុបុរាណដែលគេប្រមូលបានថែរក្សា និងជួសជុលប្រាង្គប្រាសាទបុរាណខ្មែរ។

**អាជ្ញាធរ «អប្សរា»**
ជាស្ថាប័នសាធារណៈ បង្កើតឡើងនៅឆ្នាំ១៩៩៥ ដើម្បីការពារ និងរៀបចំតំបន់អង្គរ។

នៅឆ្នាំ១៤៣១ ព្រះបាទពញាយ៉ាតបានចាកចោលអង្គរ។ ចាប់ពីពេលនោះមក មានតែប្រាសាទអង្គរវត្តទេ ដែលខ្មែរតែងទៅគោរពបូជាពុទ្ធសាសនាជាហូរហែនោះ។ ឯប្រាសាទផ្សេងៗបានត្រូវបោះបង់រហូតលិចបាត់ទៅក្នុងព្រៃព្រឹក្សា។

## ▶ ការរកឃើញអង្គរឡើងវិញដោយព្រះរាជាខ្មែរ

ព្រះបាទចន្ទរាជា នៅរវាងឆ្នាំ១៥៥០ បាននាំបរិពារទៅគង់នៅតំបន់អង្គរមួយរយៈ។ បន្ទាប់មកនៅឆ្នាំ១៥៧០ ព្រះរាជបុត្រានាមបរមរាជា ពេលរៀបចំសង្គ្រាមច្បាំងនឹងសៀម បានទៅគង់នៅកំពង់ក្រសាំងជិតប្រាសាទអង្គរវត្ត។ព្រះអង្គបានយាងទៅទតប្រាសាទនៅអង្គរធំផងដែរ។ ឯព្រះបាទសត្ថាទី១បានវិលទៅគង់នៅប្រាសាទអង្គរវត្ត បានចាត់អោយគេជួសជុលបំរុងប្រាសាទអង្គរវត្ត ហើយបានចារសិលាចារឹកទុកនៅទីនោះ។

## ▶ ការរកឃើញអង្គរឡើងវិញដោយពួកបស្ចិមប្រទេស

នៅសតវត្សទី១៦(ក្នុងរាជ្យព្រះអង្គចន្ទ) ពួកប៉័រទុយកាល់និងពួកអេស្ប៉ាញបានចូលមកកម្ពុជា ហើយអ្នកខ្លះបានទៅមើលប្រាសាទអង្គរ។ ជូក្វ ជុ គូតូ ជាតិប៉័រទុយកាល់ បានទៅមើលរាជធានីចាស់នេះនៅស.វ.ទី១៧ ហើយបានហៅប្រាសាទអង្គរថា «ជាវត្ថុវិសេសវិសាលបំផុត»។ ឯបព្វជិត ល្វីសឺវ្រ៉ឺយ នៅស.វ.ទី១៨ បានហៅប្រាសាទថា «វត្ត»។ បព្វជិត





ការជួសជុលបណ្ណាល័យខាងជើងនៃប្រាសាទអង្គរវត្ត (២០០៤)

**អាណាស្ទីឡូ**
ជាវិធីជួសជុលប្រាង្គប្រាសាទបុរាណបង្កើតឡើងដោយអ្នកឯកទេសជាតិហូឡង់នៅកោះជ្វា ហើយនាំចូលមកស្រុកខ្មែរនៅឆ្នាំ១៩៣០។ វិធីនេះប្រើដុំថ្ម ដែលរុះមកនៅរាត់រាយលើដី រឹកនៅសល់លើប្រាសាទមកសង់ប្រាសាទឡើងវិញទៅតាមរចនាបថដើមរបស់វា។ គេប្រើសំភារៈថ្មី សំរាប់តែបំពេញកន្លែងខ្វះចន្លោះតែប៉ុននោះ។

**សិលាចារឹកទំនើបអង្គរ**
គឺជាសិលាចារឹកចំនួន៤០ផ្ទាំងជាភាសាខ្មែរដែលមានចុះកាលកំនត់ពីស.វ.ទី១៦ ដល់ស.វ.ទី១៨ ដែលគេបានចារទុកនៅប្រាសាទអង្គរវត្ត។ សិលាចារឹកទាំងនោះចារឡើងដោយសមាជិកព្រះរាជវង្ស និងពួកមន្ត្រី នៅពេលពួកគេមកធ្វើបុណ្យនៅអង្គរ។

សាលអេមីល ប៊ុយើវ៉ូ បានបោះផ្សាយពីទស្សនកិច្ចរបស់លោកនៅប្រាសាទអង្គរធំ ក្នុងឆ្នាំ១៨៥០។ ដប់ឆ្នាំក្រោយមក ហង់រី មូហូត ជាតិបារាំងបានមកមើលប្រាសាទបាក់បែកនៅអង្គរ ហើយអត្ថបទពណ៌នាលំអិតនិងរូបគំនូររបស់គាត់បានធ្វើអោយសាធារណជននៅអឺរ៉ុបបានដឹងពីអង្គរ។

## ▶ ការថែរក្សា និងការជួសជុលប្រាសាទ

នៅឆ្នាំ១៩០៧ សាលាបារាំងចុងបូព៌ាប្រទេសចាប់ផ្តើមបញ្ជូនក្រុមអ្នកប្រាជ្ញមកសិក្សា និងអភិរក្សប្រាង្គប្រាសាទខ្មែរ។ ដោយសារពេលវេលា អាកាសធាតុ ព្រៃឈើ អាចម៍និងទឹកនោមសត្វប្រជៀវ និងការលួចវត្ថុបុរាណ ប្រាសាទបានខូចខាតយ៉ាងខ្លាំង។ នៅឆ្នាំ១៩៣០ ទើបគេបានយកវិធីអាណាស្ទីឡូមកប្រើ។ ប្រាសាទបន្ទាយស្រីបានត្រូវជួសជុលលើកទី១ពីឆ្នាំ១៩៣០ដល់១៩៣៤ ដោយប្រើវិធីនេះ។ ព្រមជាមួយគ្នាដែរ អ្នកប្រាជ្ញសាលាបារាំងចុងបូព៌ា និងអ្នកស្រាវជ្រាវឯទៀតបានសិក្សាប្រាសាទ សិលាចារឹក ធ្វើបញ្ជីប្រាសាទ សរសេរប្រវត្តិសាស្ត្រ ប្រវត្តិសិល្បៈខ្មែរ។ ក្នុងសង្គ្រាមស៊ីវិលនិងរបបខ្មែរក្រហម ការជួសជុលបានត្រូវផ្អាក។ នៅឆ្នាំ១៩៩២ ប្រាសាទអង្គរបានត្រូវបញ្ចូលទៅក្នុងបេតិកភណ្ឌពិភពលោករបស់មនុស្សជាតិ នៅក្រោមការគ្រប់គ្រងរបស់អង្គការយូណេស្កូ។ ការប្រឹងប្រែងថ្នាក់ជាតិនិងអន្តរជាតិកំពុងបន្តដើម្បីអភិរក្សនិងជួសជុលប្រាង្គប្រាសាទ។



សិលាចារិកទំនើបអង្គរ IMA 03a នៅថែវព្រះពាន់ប្រាសាទអង្គរវត្ត

# ផែនទី

## ការបាត់បង់ទឹកដីកម្ពុជាក្រោម




### សាកល្បង រកចំលើយ

ទឹកដីកម្ពុជាក្រោមទាំងមូល មានផ្ទៃក្រលាប្រមាណ

ក-២០ ០០០ គម² ?

ខ-៤០ ០០០ គម² ?

គ-៦០ ០០០ គម² ?

ចំលើយ : ទំព័រ៤៤






**ក**

**កម្ពុជាតាមសន្ធិសញ្ញាឆ្នាំ១៩០៧**

ទឹកដីខ្មែរដែលសៀមបានប្រគល់អោយខ្មែរវិញនៅឆ្នាំ១៩០៧

ព្រំដែនបច្ចុប្បន្ន




**ខ**

**កម្ពុជាតាមសន្ធិសញ្ញាក្រុងតូក្យូ ចុះថ្ងៃ១១ មីនា ១៩៤១**

ដែនដី ដែលសៀមបានរឹបអូសយកដោយមានការគាំទ្រពីជប៉ុន

ព្រំដែនបច្ចុប្បន្ន

# ពន្យល់ពាក្យ

**កែន** ប្រមូលហៅរកដោយអាជ្ញា។

**ចាកសិក្ខាបទ** សឹក គឺផ្លាស់ភេទពីបព្វជិត (អ្នកបួស)មកជាគ្រហស្ថ (អ្នកមានគ្រួសារ)។

**ព្រែកភាជ្យ** ដណ្ដើមរាជ្យ, ដណ្ដើមសោយរាជ្យ។

**ធម្មទេសនា** ការសំដែងធម៌។

**ធ្វើគុត** ពិឃាត, ធ្វើឃាត, សំលាប់។

**បណ្ណាការ** ជំនូន, ភ័ស្ដុភារ, តង្វាយ។

**បរិច្ចាគ** លះបង់ទ្រព្យដើម្បីធ្វើទាន។

**ពហុស្សុត** ដែលរៀនបានច្រើន, ដែលមានចំនេះដឹងច្រើន។

**មហារាជ** ស្ដេចធំ។

**រជ្ជទាយាទ** អ្នកដែលត្រូវទទួលរាជសម្បត្តិជាមរតក, រាជបុត្រដែលបំរុងនឹងបានសោយរាជ្យ។

**សហភាព** រដ្ឋទាំងឡាយ ដែលប្រមូលផ្ដុំគ្នាដើម្បីស្ថិតនៅក្រោមរដ្ឋាភិបាលតែមួយ រឺដើម្បីការពារផលប្រយោជន៍រួម។

**សួយ** តង្វាយ, ជំនូន, ប្រាក់ពន្ធ។

**សួយសារអាករ** ជំនូនដែលនាំឡើងមានសំបុត្រជាផ្លូវរាជការអមផង។

**សំណព្វ** អ្នកដែលគាប់ចិត្ត។

**សញ្ជ័យ** ការឈ្នះស្រេចបាច់, ការបង្ក្រាបសត្រូវបាន។

**ស្វយ័ត** ដែលមានសេរីភាពចាត់ចែងកិច្ចការគ្រប់យ៉ាងដោយច្បាប់របស់ខ្លួន។

**អធិជ័យ** ជ័យជំនះយ៉ាងធំ, យ៉ាងសំបើម។

**អត្តសញ្ញាណ** គ្រឿងសំគាល់ខ្លួន។

**អធិរាជ** មហារាជ, ព្រះរាជាជាធំចំបងជាងព្រះរាជាទាំងឡាយក្នុងប្រទេសជិតខាង។

**អាណាខេត្ត** ខេត្តដែលនៅក្នុងការគ្រប់គ្រងនៃមហាក្សត្រ រឺ រដ្ឋបាលណាមួយ។

**អាណាព្យាបាល** ការគ្រប់គ្រងរក្សា រឺអ្នកគ្រប់គ្រងរក្សា។

**ឧបរាជ** ព្រះរាជាបន្ទាប់។

**យើងប្រើ :**

- ពាក្យ**សៀម**រហូតដល់ឆ្នាំ១៩៣៩ (រដ្ឋាភិបាលយោធាឡើងកាន់អំណាច) និងពាក្យ**ថៃ**បន្ទាប់មកទៀត។
- ពាក្យ**លាវ**រហូតដល់ឆ្នាំ១៩៧៥ (រដ្ឋាភិបាលកុំមុយ-នីសឡើងកាន់អំណាច) និង**ឡាវ**បន្ទាប់មកទៀត។
- ចំពោះវៀតណាម :
  - ពាក្យ**ដាយវៀត** រហូតដល់ឆ្នាំ១៨០២។
  - ពាក្យ**តុងកឹង, អណ្ណាម** និង**កូសាំងស៊ីន** (កម្ពុជាក្រោម) ក្នុងសម័យអាណាព្យាបាលបារាំងរហូតដល់ឆ្នាំ១៩៤៥ (ហូជីមិញប្រកាសឯករាជ្យ) និងពាក្យ**វៀតណាម**បន្ទាប់ពីនោះមក។
  - ពាក្យ**អណ្ណាម** សំគាល់ផ្នែកកណ្ដាលនៃប្រទេសវៀតណាម។ ជាយូរមកហើយពាក្យអណ្ណាមសំគាល់ប្រទេសទាំងមូលជាពិសេសសំរាប់ជនជាតិចិន។

# ? ចំលើយ

- **ទំព័រ៧** : គ
- **ទំព័រ១០** : ក
- **ទំព័រ១៤** : គ។
- **ទំព័រ១៧** : ខ និង គ
- **ទំព័រ២០** : គ
- **ទំព័រ២៤** : ក និង ខ
- **ទំព័រ២៩** : គ
- **ទំព័រ៣៤** : ខ (ត្រង់កន្លែងស្ពានសព្វថ្ងៃ)
- **ទំព័រ៣៨** : ក
- **ទំព័រ៤២** : គ